# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែមករា លេខ ១

ព. ស. ២៤៩៣ – គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| ប្រវត្តិសាស្ត្រនៃស៊ីវិល្បែខ្មែរបុរាណ(តចប់) | លោក ប៉ាយ-ប៊ុក | ៣ |
| សព្វបាវ៉ាំងប្រែជាខ្មែរ (តមក) | — ម៉ុញ-នាត្រី | ១០ |
| រឿងព្រេងភូមា (តមក) | — សាង-សាវ៉ាត | ១៤ |
| រឿងសាមកុក (តមក) | — ឡូ-កន | ២៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | — ឈឹម-ក្រសេម | ៣៥ |
| សាវតារវត្តបាជិនារាម (តចប់) | ព្រះវិនយធរគណ | ៤៣ |
| ប្រវត្តិអេសុប (តចប់ | លោក ផេង-ជ័រ | ៥២ |
| **ផ្នែកសាសនា** | | |
| ពន្លឺអាស៊ីទិប (តមក) | លោក ប៉ាយ-ប៊ុក | ៦២ |
| ឧបក្កលេស ១៦ ពាក្យកាព្យ | — យូរ-អ៊ុន | ៦៧ |
| **កំណត់ទីនប្រវត្តិការណ៍** | | |
| ពិធីទទួលសម្តេចសង្ឃនាយក ជួន-ណាត | | |
| នៅវត្តដំណាក់ (សៀមរាប) | ព្រះមហាកែ-អៀន | ៧៤ |
| បញ្ជីរាយនាមចៅអធិការតាំងថ្មី (តមក) | ក្រសួងធម្មការ | ៧៩ |


មួយឆ្នាំមាន ១២ សៀវភៅ ជាថ្លៃជារ . . . . . . . . . . . . . . . . ១៤៥រ,០០

# KAMBUJASURIYA

Revu religieuse et littéraire éditée par l'Institut Bouddhique.

## *TABLE DES MATIÈRES*

### PARTIE LITTERAIRE


| | | Pages |
|---|---|---|
| Histoire de l'ancienne civilisation Khmère (suite et fin) ........ | *M. RAY-BUC* .......... | 3 |
| Recueil des mots traduits par la Commission Culturelle (suite) . | *M. MENH-NAKRY* ....... | 10 |
| Contes birmans ............... | *M. SANG-SAVAT* ....... | 14 |
| Histoire de SAMBOK (suite) .... | *M. NOU-KAN* .......... | 23 |
| Histoire du Royaume du Cambodge (suite .................... | *M. CHHIM-KRASEM* ..... | 35 |
| Nolice historique de la pagode de Pacinarama (suite et fin) ..... | *PREAH VINAYADHARA GANA* .......... | 43 |
| Biographie d'ESOPE (suite et fin) | *M. PHENG-CHRIEU* ...... | 52 |


### PARTIE RELIGIEUSE


| | | |
|---|---|---|
| La Lumière de l'Asie (suite) .... | *M. RAY-BUC* .......... | 62 |
| Seize Upakilesa (Poème)......... | *M. YOU-OUN* .......... | 67 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Réception de SON EMINENCE le Chef de la Secte Mohanikay à la pagode de Damnak (Siemreap) | *PREAH MOHA KER-ŒUN* ... | 74 |
| Nomination des nouveaux Chau-Athicar (suite) . .............. . | *MINISTERE DES CULTES* .... | 79 |


Prix d'un abonnement annuel comprenant 12 numéros: 145$00

ប្រវត្តិសាស្ត្រនៃស៊ីវិល្ស៊ែខ្មែរបុរាណ

លោក សិរស៍-ស៊ីដែស តែង

# លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ត បទ)

---

ពួកស្ត្រីមិនមែនបោះបង់ការសិក្សាទេ ហើយមានស្ត្រីខ្លះព្យាយាមរៀនសូត្រជាងគេក៏មាន ៗ នៅចុងសតវត្សទី ១២ មានសិលាចារឹកមួយថ្លែងថា "មានព្រះអគ្គមហេសីក្សត្រីមួយអង្គ មានប្រាជ្ញាបេះដោះជាងចំណោះពួកទស្សនវិទូទៅទៀត ហើយព្រះមហាក្សត្រិយ៍បានតែងតាំងព្រះនាងជាសាស្ត្រាចារ្យនាយិកានៅវត្តព្រះពុទ្ធសាសនាមួយ ដែលមានកិត្តិនាមល្បីល្បាញអស្ចារ្យ មានមុខងារនាទីបង្ហាត់បង្រៀនពួកនារីទាំងអស់ ៗ កន្លងបន្តិចមកព្រះនាងបានឡើងឋានន្តរស័ក្តិជាព្រះអគ្គជាយាមួយអង្គ, តែព្រះនាងខត្តិយានី មិនបានបោះបង់បោលពួកនិស្សិតដែលព្រះនាងធ្លាប់បង្ហាត់ពីពេលមុនមកទេ ៗ តាមសិលាចារឹកពោលថា "ចំពោះបណ្តាពួកស្ត្រីដែលពេញចិត្តខាងរៀនវិទ្យា, ព្រះនាងបានផ្សាយព្រះកិត្តិសព្ទព្រះមហាក្សត្រិយ៍ពង្រីកគ្រប់ភូមិភាគជនបទ ដោយព្រះនាងប្រើប្រាជ្ញា ដែលគេប្រៀបដូចជាទឹកអម្រឹត្យ មានឧជារសដ៏វិសេសវិសាលពន់ពេក" ៗ គេបានឃើញនូវស្នាព្រះហស្តរបស់ព្រះនាងគឺពាក្យនិទានរឿង ដែលជាងបានឆ្លាក់គង់នៅលើផ្ទៃសិលាមួយ ដែលគេបានរកឃើញនៅខាងក្នុងព្រះបរម-

រាជវាំងអង្គរធំ, និទាននោះ ព្រះនាងបានតែងជាពាក្យកាព្យអក្សរសំស្ក្រឹត ពីរោះគាប់ចិត្តណាស់ ។

ដើម្បីនឹងពន្យល់អំពីលក្ខណៈឥណ្ឌានៃស៊ីវិឡ្យៃក្នុងពេលនោះ ដែលខ្ញុំបានពណ៌នាត្រង់គោលសំខាន់ៗ គេបានព្រមព្រៀងគ្នាថាប្រជារាស្ត្រខ្មែរដើម មកពីប្រទេសឥណ្ឌា ។ បើពិនិត្យតាមចរិតឬលក្ខណ នៃរូបភាពនឹងភាសាជាតិ, ជាតិខ្មែរដែលជាអ្នកស្ថាបនាប្រាសាទអង្គរព្រមទាំងពលរដ្ឋប្រទេសកម្ពុជាសម័យបច្ចុប្បន្ន គឺ ជាជាតិក្នុងវង្សប្រជាជាតិ ដែលនៅក្នុងឧបទ្វីបឥណ្ឌូចិន តាំងពីសម័យបុរាណ, ហើយបើទុកណាជាក្នុងកំឡុងដែលពួកជាតិឥណ្ឌាបានចូលមកតាំងនៅក្នុងប្រទេសនេះ តាំងពីសតវត្សទីមួយនៃគ្រិស្តសករាជ, ក៏អក់ជនខ្មែរនោះមានលោហិតជាតិឥណ្ឌូខ្លះមកលាយជាមួយតាំងពីសម័យអង្គរ ។ គេមិនត្រូវយល់ថាថ្នាក់ប្រជាជាតិដែលត្រួតត្រានៅទីនេះ (ឥស្សរជន) ជាប្រជាជាតិដោយឡែកពីពួកពលរដ្ឋៈនោះឡើយ ។ តាមរូបចំឡាក់ គេបានឃើញភាពទ្រង់ទ្រាយមុខជាខ្មែរ ហើយមានឈ្មោះជាខ្មែរដូចគ្នា ។

គេអាចពោលបានថា ស៊ីវិឡ្យៃខ្មែរបុរាណជាស៊ីវិឡ្យៃមួយដែលកើតមកពីស៊ីវិឡ្យៃឥណ្ឌូជាប្រថម ហើយមានសភាពលាយឡំគ្នានឹងស៊ីវិឡ្យៃនៃពលរដ្ឋឥណ្ឌូចិន ។ ស៊ីវិឡ្យៃនោះជាឥណ្ឌូ ដូចស៊ីវិឡ្យៃបារាំងជាឡាទិន (គឺមកពីជាតិរ៉ូម៉ាំង) ដោយមានលក្ខណៈប្លែកគ្នា គឺចម្ងាយនៃស៊ីវិឡ្យៃ

ឥណ្ឌូនឹងស៊ីវិល្ល័យខ្មែរជាន់ដើមនោះ មានសភាពធ្លាយជាងស៊ីវិល្ល័យម៉ាំង ដែលផ្សាយទៅកាន់ស៊ីវិល្ល័យកុល្វ៉ា ៗ គេអាចយល់បាននូវសេចក្ដីសំខាន់ ចំពោះពលរដ្ឋខ្មែរក្នុងកម្រិតភាពនៃស៊ីវិល្ល័យ (ប្រទេសឥណ្ឌូ) ដោយបាន សង្កេតការណ៍ដែលខ្ញុំបានពណ៌នាក្នុងសៀវភៅខ្ញុំ ឈ្មោះប្រវត្តិសាស្ត្រ សម័យបុរាណនៃរដ្ឋជាតិឥណ្ឌូ) (Histoire ancienne des Etas hindouisés) ៗ បើតាមលក្ខណៈនៃរូបនិយម, អ្នកស្រុកខ្មែរមិនខុសគ្នាពីជាតិ ពួងឬជាតិសំរែ តែជាតិពួងដូចជាតិម៉ាយនៅប្រទេសយួនទៅខាងថ្នាក់ នៃអង្គការកុលសម្ពន្ធ; ជាតិនេះបានផ្សះផ្សារឿងឈ្មោះទាស់ទែងគ្នាតាម ទំនៀមទម្លាប់ដែលនិយាយតៗ គ្នាមក, ពួកកុលសម្ពន្ធនេះកាន់សាសនា អទិស្សមានកាយលទ្ធិជឿភូតបិសាច (Animisne); លោកធាតុវិន័យ គឺការយល់នូវបទបញ្ញត្តិដែលសត្វលោកនៅក្នុងចក្រវាឡត្រូវប្រតិបត្តិតាម (Cosmologie) នោះតិចតួចស្ទួចស្ដើងណាស់; ជាតិទាំងនេះមិនមានអក្សរ សម្រាប់សរសេរភាសាខ្លួនទុកឡើយ ៗ តែខ្មែរដែលនៅវិវត្តន៍អន់ទន់ ខ្សោយក៏ដោយ បានចូលមកជាច្រើនសតវត្សតៗមក ក្នុងក្រៀងចក្រ នៃរដ្ឋតាមថ្នាក់តាមជាន់; ខ្មែរទាំងនោះ បើត្រូវគេចោទក្នុងរឿងក្ដីមួយៗ មានសាលាកាត់សេចក្ដីតាមច្បាប់ដែលមានអក្សរសរសេរស្រាប់ ហើយ បានកាន់យ៉ាងម៉ាំមួននូវសាសនាដែលមានឡាក់គោលច្បាស់លាស់, មាន គម្ពីរ មានទាំងព្រះសង្ឃដែលជាអ្នកបង្ហាត់បង្រៀននូវវិទ្យាលោក

វិទ្យានិងបរលោក ព្រមទាំងរឿងរ៉ាវដែលទាក់ទងនៅក្នុងចំណោមនៃមនុស្សធម៌ក្នុងអាស៊ីទ្វីប ។ ក្រៅពីនោះ ជាតិខ្មែរមានរបៀបអក្សរដែលជាហេតុឲ្យកើតមានអក្សរសាស្ត្រ អាចឲ្យមានផ្លូវគមនាគមន៍ប្រស័យគ្នាចំពោះប្រទេសជិតខាង ។ កិច្ចការទាំងអស់នេះ កើតឡើងដោយសារបានផ្ទេរស៊ីវិល្យមកពីប្រទេសឥណ្ឌា ។

បឋមហេតុនៃស៊ីវិល្យខ្មែរ យើងស្រាវជ្រាវបានយល់ខ្លះ ។ ការណ៍ដែលខ្មែរធ្លាក់ចុះអាប់រស្មីពីកាលសតវត្សរ៍ទី ១៤, គេបានស្មាននូវហេតុនោះដោយពោលពាក្យមិនគប្បីនឹងឲ្យជឿបាន គេថាមកពីគ្រឡាប់ប្រថពីឬមកពីឧទកភ័យ ឬក៏មកពីប្រែប្រួលអាកាសធាតុដែលនាំឲ្យប្រទេសកម្ពុជាគោកទឹក ។ បើតាមពិនិត្យ, ក្នុងសតវត្សរ៍ទី ១៣ មានគណៈប្រតិភូចិនម្នាក់ដែលបានមកទស្សនាការប្រទេសកម្ពុជា បានកត់ត្រាទុកថាមានហេតុពីពេលនោះ គួរសំគាល់បាននូវហាយនភាពនៃជាតិខ្មែរក្នុងកាលជាអនាគត ។ ប្រតិភូចិនបានកត់ត្រាថា: ក្នុងសង្គ្រាមចំពោះប្រទេសសៀម, ស្តេចខ្មែរបានបង្គាប់ទៅពលរដ្ឋទាំងអស់ឲ្យចូលតស៊ូ ហើយថាប្រទេសខ្មែរក្នុងពេលនោះត្រូវសៀមមកលុកលុយជាច្រើន ។ សង្គ្រាមនោះ មានក្នុងរយៈវេលាមិនដល់មួយសតវត្ស គិតតាំងពីការកសាងនូវប្រាសាទសម្រាប់បញ្ចុះព្រះសពមានប្រាសាទអង្គរ (នគរ) ជាដើមនៃមហាកជពីសតវត្សទី ១២ ។

មានការកេណ្ឌប្រជារាស្ត្រ ដើម្បីកសាងនូវព្រះស្តូបចេតិយ (ប្រាសាទ) ទាំងនោះ, រួមមានសង្គ្រាមជាច្រើនលើក នាំឲ្យពលរដ្ឋខ្មែរព្រួយលំបាកជាខ្លាំង ហើយបច្ចាមិត្តដែលមានជោគជ័យក្នុងការសង្គ្រាមនេះ បានធ្វើឲ្យចំនួនប្រជាជនខ្មែរអន់ថយចុះ ដោយនាំយកទៅជាឈ្លើយច្រើននាក់, ការទុព្វលភាពនូវរាជការកណ្តាល ដោយហេតុមកពីការមិនថែទាំនូវធារាសាស្ត្រនៃប្រទេស, ហើយចុងក្រោយបង្អស់ មានការបោះបង់ចោលនូវព្រះរាជធានីក្នុងសតវត្សទី ១៥, នេះជាឡាក់គោលដែលពន្យល់អំពីការមានរាសីចុះអាប់ស៊ីវិល្វៃសម័យអង្គរ ។ ស៊ីវិល្វៃនៃប្រទេសកម្ពុជាសម័យទំនើបនេះ គឺផ្ដិតយកពីស៊ីវិល្វៃអង្គរ ហើយកិច្ចការដែលធ្វើឲ្យយើងកាន់តែភ្លឺក្នុងរឿងនេះ ដោយបានអាននូវសារណា (mémoire) នៃទំនៀមទម្លាប់ប្រទេសកម្ពុជាដែលអ្នកដំណើរចិនបានតែង ទៅឃើញមានពិពណ៌នាខ្លះ នឹងយោបល់ខ្លះ ល្មមយកមកអនុវត្តន៍នូវស្ថានការណ៍នៃប្រទេសកម្ពុជាក្នុងសតវត្សទី ២០ នេះបានដែរ ។

ស៊ីវិល្វៃសៀមដែលមានតាំងពី គ. ស. ១២៥០ ឬ ១៣៥០ សុទ្ធតែបានមកពីស៊ីវិល្វៃសម័យអង្គរទាំងអស់ ។ ប្រទេសកម្ពុជា ដែលជានាយកលើប្រទេសសៀមជាច្រើនសតវត្ស, ជាតិសៀមបានផ្ទេរយកអង្គការនយោបាយអក្សរដែលបានមកពីអក្សរហិណ្ឌូ, នឹងពាក្យខ្មែរជាច្រើន; ពួកសិល្បករសៀមបានផ្ទេរយកវិទ្យាសិល្បាករពីខ្មែរ ហើយយកទៅរចនាតាមប្រាជ្ញារបស់ខ្លួន ។

ប្រទេសកម្ពុជាបានផ្សាយឥទ្ធិពលទៅដល់ប្រទេសលាវ ដោយសារព្រះពុទ្ធសាសនា ។ ព្រះរាជអាណាចក្រលាវបានស្ថាបនាឡើងក្នុងលោកពី គ. ស. ១៣៥៣ មានរាជជនកគឺព្រះអង្គម្ចាស់ ហ្វា-ង៉ុំ ដែលមហារាជសម័យអង្គរបានយកមកបីបាច់រក្សានៅក្នុងព្រះបរមរាជវាំង ដោយមានព្រះបិតានៃព្រះអង្គម្ចាស់នេះ ទ្រង់បានចាកចេញពីប្រទេសចូលមកសុំពំនាក់អាស្រ័យនៅទីនោះ ។ ព្រោះហេតុដូចនេះ បានជាមានបញ្ញាលស៊ីវិល្បខ្មែរទៅឯទន្លេមេគង្គខាងលើ ។ ដល់សោយរាជ្យបានយូរបន្តិច, ព្រះមហាក្សត្រិយ៍លាវនេះបានចាត់ នូវបេសកកម្មមួយ ដែលមានគិក្ខុមួយអង្គជាអាចារ្យរបស់ទ្រង់ឲ្យចេញពីប្រទេសកម្ពុជា ហើយមានព្រះសង្ឃនឹងពួកជាងរបនាគូឆ្លាក់ទៅជាមួយផង ដើម្បីនឹងផ្សាយនូវវិទ្យាខាងសាសនានឹងសិល្បកម្មចំពោះប្រទេសនេះ ។

លុះដល់ជាតិខ្មែរបានឃើញអំណាចរបស់ខ្លួនថយចុះ មិនបានស្ថិតនៅក្នុងភូមិភាគទន្លេមេណាមនឹងទន្លេមេគង្គខាងលើ ក៏បានទុកឲ្យដល់ជាតិសៀមនឹងលាវនូវគេរ្តិ៍ដំណែលនៃវប្បធម៌ហិណ្ឌូ ដែលជាវប្បធម៌ជាប់ទាក់ទងពីស៊ីវិល្បបុរាណនៃប្រទេសមេសូប៉ូតាមី, ជាបុសគល់វប្បធម៌នៃបច្ចិមប្រទេស ។

បើពោលពាក្យកុំឲ្យហួសហេតុ, គេអាចពោលថាក្នុងសហរដ្ឋឥណ្ឌូចិន, ចំពោះប្រទេសយៀកណាមយកវប្បធម៌ចិនមកប្រើ, ប្រទេស

កម្ពុជា នឹងប្រទេសលាវជាគណៈប្រតិកូនៃវប្បធម៌ដែលមានសភាពដូចគ្នា នឹងវប្បធម៌របស់យើង ៗ ឯភាសាយួនដែលនឹងចំរើនបានដោយខ្ចីអក្សរសាស្ត្រចិនយកមកប្រើខ្លះ ៗ ចំណែកខាងភាសាខ្មែរហើយនឹងលាវបានយកភាសានៃប្រទេសឥណ្ឌា គឺភាសាសំស្ក្រឹតនឹងបាលីដែលចូលក្នុងវង្សភាសាឥណ្ឌូ – អឺរ៉ូប ដូចជាភាសាឡាតាំងនឹងក្រេកដែរ ៗ

ចំពោះការជាប់វង្សត្រកូលខាងភាសា ដែលប្រវត្តិសាស្ត្រនឹងភាសាសាស្ត្របានបំភ្លឺក្នុងរឿងនេះ គេអាចយល់បានថាបញ្ហានយោបាយក៏មានសភាពដូចគ្នា ដូចមានព្រឹត្តិការណ៍សម័យបច្ចុប្បន្នបានបញ្ជាក់ឲ្យឃើញភ័ស្តុតាងស្រាប់ ៗ

ចប់

---

មែនឬទេ ?

ទង់ជ័យកើតឡើងអំពីពាហិរសាសនា តែប្រជាជាតិត្រូវរក្សាទង់ជ័យនោះឲ្យដូចជាដួងវិញ្ញាណរាល់រូប ព្រោះទង់ជ័យរលត់ ជាតិក៏រលត់ ៗ

យូរ-អ៊ុន

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## លោក ម៉ុញ-ផ៉ាត្រី រួបរួម

(តមក)

---

Délégué de Sa Majesté à Siemréap = រាជប្រតិភូនៅសៀមរាប

Délégué de Sa Majesté Commandant le Secteur autonome à Siemréap = រាជប្រតិភូអ្នកបង្គាប់ការក្នុងតំបន់ស្វ័យភាពនៅសៀមរាប

Le rêve = ការយល់សប្តិ, សុបិន, វិតក្កៈ

Membre souscripteur = សមាជិកចុះស្ម័គ្រ

Droit d'entrée = ដម្លៃចូល

Cotisation = ប្រាក់អង្គាស

Subvention = ប្រាក់បន្ថែម

Service d'Enregistrement et des Timbres = ក្រុមចុះបញ្ជីទ្រព្យរាជការ នឹងតែម

Enthousiasme = សាទរ

Coup d'Etat = រដ្ឋប្រហារ

Coup de théâtre = ប្រវត្តិប្រហារ

Çoup de force = ពលប្រហារ

Commando de contre-guérilla = កងពិសេសទល់ទ័ពព្រៃ

Acte de préméditation = អំពើដែលគិតទុកជាមុន

Indécision = ការណ៍មិនដាច់ស្រេច

(៦-៦-៥០)

Fidèle = ភក្តី

Fidèlité = ភក្តីភាព

(៣០-២-៥១)

Titre d'identité = អត្តសញ្ញាណប័ណ្ណ

Carte d'identité = ប័ណ្ណសំគាល់ខ្លួន

Rapport = សេចក្តីរាយការ

Rapporteur = អ្នករាយការ - អ្នកនាំការ

Signaler = ធ្វើសញ្ញាប្រមាន

(៣-៣-៥០)

Durée = កំឡុងពេល (ចិរវេលា)

Automatique = ស្វ័យប្រវត្ត

Assurer = រ៉ាប់រង

L'ostréiculture = សិប្បវប្បកម្ម (ការចិញ្ចឹមគ្រំ)

La sylviculture = រុក្ខវប្បកម្ម (ការបណ្តុះបណ្តាលព្រៃ)

La sériciculture = កោសេយ្យវប្បកម្ម (ការចិញ្ចឹមនាង)

(១១-៣-៥០)

L'aviculture = បក្សីវប្បកម្ម (ការចិញ្ចឹមសត្វស្លាប)

L'horticulture = អារាមវប្បកម្ម (ការដាំសួន)

L'apiculture = មធុវប្បកម្ម (ការចិញ្ចឹមឃ្មុំ)

La puériculture = ទារកវប្បកម្ម (វិធីចិញ្ចឹមទារក)

La piscicuture = មច្ឆវប្បកម្ម (ការចិញ្ចឹមត្រី)

L'ostréiculteur = សិប្បិវប្បករ

Le sylviculteur = រុក្ខវប្បករ

Le sériciculteur = កោសេយ្យវប្បករ

L'horticulteur = អារាមវប្បករ

L'aviculteur = បក្សីវប្បករ

Un automate = ស្វ័យប្រវត្តក៍ (ដែលប្រព្រឹត្តទៅខ្លួនឯង,
មនុស្សដែលធ្វើការដោយមិនបាច់គិត)

Robot = ស្វ័យគម (ដែលទៅខ្លួនឯង)

Avion téléguidé = យន្តហោះទូរណ័ត្ត (យន្តហោះដែលប្រើពីចម្ងាយ)
(២១-៧-៥០)

Nom posthume = មរណនាម, នាមបច្ឆាមរណៈ

Livre posthume = សៀវភៅបច្ឆាមរណៈ

Fils posthume = បុត្របច្ឆាមរណៈ

Enfant posthume = កូនបច្ឆាមរណៈ

A titre posthume = ជាកិច្ចបច្ឆាមរណៈ

Lâche = កំសាក

Lâchement = ដោយកំសាក

La lâcheté = សេចក្ដីកំសាក

Hélicoptère = ឧទ្ធម្ភាគចក្រ

(២៥ - ៣ - ៥០)

Administrer = គ្រប់គ្រង

Carte administrative = ផែនទីរដ្ឋបាល

Carte provinciale = ផែនទីខេត្ត

Carte routière = ផែនទីគមនាគមន៍

Carte politique = ផែនទីប្រជាគណន៍

Carte physique = ផែនទីរូបនិយម

Carte économique = ផែនទីសេដ្ឋកិច្ច

Route nationale = ថ្នល់ជាតិ

Route provinciale = ថ្នល់ខេត្ត

Route communale = ថ្នល់ឃុំ

(៤ - ៨ - ៥០)

(អាឧត)

## រឿងព្រេងភូមា

# លោក សាង-សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

---

នាយសួនក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស! ព្រោះកាលពីថ្ងៃមុនមិនសូវមានសត្វដូចសព្វថ្ងៃនេះ, តែឥឡូវនេះមានសត្វសេកមួយរុករានបំផ្លាញពេកណាស់, ទូលព្រះបង្គំដេញចាប់វាពុំបានសោះ" ។ ស្ដេចក៏មានព្រះរាជឱង្ការសួរទៀតថា "មែនឬ? បើមែនអញនឹងប្រមូលពួកព្រានដែលនៅក្នុងវាំងទាំងប៉ុន្មានមកដើម្បីឲ្យធ្វើអន្ទាក់ចាប់វាឲ្យបានក្នុងពេលឆាប់ៗនេះ" ។

មិនយូរប៉ុន្មានទេ បក្សាកំសត់នោះក៏ត្រូវគេចាប់បានមែន ។ ប៉ុន្តែអស់ពួកព្រានព្រៃដោយឃើញសេកនេះល្អ ក្អែករលោង ពណ៌ស្រស់ក៏មានចិត្តមេត្តាករុណាជាក្រៃពេកដល់បក្សា ហើយបានយកទាំងរស់ទៅថ្វាយព្រះរាជា ។ លុះទ្រង់ទតឃើញថាសេកនេះល្អ ស្ដេចក៏យកទៅប្រទានដល់ព្រះរាជបុត្រីព្រះអង្គ ។ ឯព្រះរាជធីតាមានព្រះរាជហឫទ័យស្រឡាញ់សេកនោះពន់ពេក ហើយព្រះនាងយកទៅថែរក្សាផ្ទាល់ព្រះអង្គ ។ មួយថ្ងៃៗ ព្រះនាងតែងលេងជាមួយ កាន់អង្អែលមិនឈប់មិនឈរឡើយ ។ មានថ្ងៃមួយ ព្រះនាងយកសេកនោះទៅដាក់

លើក្បាលផ្កន់ព្រះនាង ស្រាប់តែនាងឃើញខ្សែសូត្រតូចឆ្មារុំនៅក, ព្រះនាងខ្វាចបក្សាអផ្សុកក៏ស្រាយខ្សែនោះចេញ ។

លុះស្រាយរួចភ្លាម បក្សាក៏ក្លាយកេទទៅជាបុរសមួយយ៉ាងស្អាត មុខមាត់សមសួន រាងរៅធេតធាយ ។ ព្រះនាងនឹកចូលណាស់ ហើយ ព្រះនាងដើរទៅជិតបុរស យកខ្សែនោះទៅចងកឲ្យវិញដូចពីមុន ។ ស្រាប់តែបុរសក្លាយខ្លួនជាសត្វសេកវិញភ្លាម ។ លុះដឹងរឿងនេះសព្វគ្រប់កាលណា ព្រះនាងញញឹម ហើយមានព្រះហឫទ័យស្មោះស្ម័គ្រលើរូបបុរសនោះពន់ពេក ។ ព្រះនាងនឹកទៀតថា មុខជាបានរួមរស់រួមរ៉ាសនានឹងបុរសនេះដោយឥតស្រីស្នំណាមួយដឹងឡើយ ។

កល់ពត្រីព្រះនាងស្រាយខ្សែសូត្រ ហើយនៅរួមរសមេត្រីជាមួយនឹងបុរសយ៉ាងក្សេមក្សាន្ត ។ លុះភ្លឺឡើងព្រះនាងចងខ្សែនោះទៅវិញ ។ ព្រះនាងអង្អែលសេកនោះលេងមិនចេះអស់ព្រះទ័យឡើយ ។

ជនទាំងពីរនេះនៅជាមួយគ្នាយ៉ាងសប្បាយអស់កាលជាច្រើនខែ ។ ប៉ុន្តែមនុស្សសត្វនៅនាលោកនេះ បើមានសុខហើយ តែងមានទុក្ខផង គ្មានអ្វីស្ថិតស្ថេរយូរអង្វែងទេ ។ ថ្ងៃមួយនោះ គេបានសង្កេតឃើញរូបកាយព្រះនាងដែលស្តើងតូច ក្លាយទៅជាខុសធម្មតាស្ត្រីព្រហ្មចារី បីដូចបុប្ផាដែលត្រូវកំដៅព្រះអាទិត្យ ប៉ុន្តែគ្មានអ្នកណាមួយអាចដឹងដល់ការណ៍អាថ៌កំបាំងនេះឡើយ ។

រឿងនេះបានជ្រាបដល់ព្រះមហាក្សត្រ ស្ដេចមានព្រះហឫទ័យ ងឿងឆ្ងល់ ហើយខ្មាសអៀនជាពន់ពេក ។ ព្រះអង្គទ្រង់ត្រាស់បង្គាប់ ឲ្យលោកទៅក្រមអង្កេតមើលភ្លាម (ព្រោះកាលនោះគេនិយមធ្វើអង្កេត ដូចសព្វថ្ងៃនេះដែរ) ឯក្នុងសម័យនេះមានតែការផ្ដេសផ្ដាសទេដែលនាំ ឲ្យរកឃើញការណ៍ពិតនោះ ។

រីឯសត្វសេក លុះកាលណាឮថាគេធ្វើអង្កេតដូច្នោះ មានចិត្ត ភិតភ័យជាខ្លាំង ហើយស្ទុះហើរពីបន្ទប់ចុះទៅក្នុងសួនច្បារដែលនៅជិត នោះ ។ ក្នុងពេលនោះ សរសៃអំបោះក៏របូតចេញពីក ដោយសារ ទំប្រឹងស្ទុះនេះ ។

បក្សាក៏ក្លាយខ្លួនទៅជាមនុស្សវិញ ហើយរត់យ៉ាងប្រញាប់ចេញពីផ្លូវ វាំង ។ បន្តិចក្រោយមក បុរសបានទៅដល់ផ្ទះមហាសេដ្ឋីម្នាក់ដែលកំពុង បរិភោគអាហារជាមួយភរិយានិងបុត្រ នៅលើកន្ទេលមួយយ៉ាងស្អាត ។

ដំបូងមហាសេដ្ឋីនេះភិតភ័យជាខ្លាំង ប៉ុន្តែក្រោយមក មានចិត្ត សង្ស័យថា បុរសនេះមិនមែនជាចោរទេ ប្រហែលមានរឿងអ្វីផ្សេងៗ យ៉ាងប្លែកហើយ ។ លោកក៏សាកសួរអំពីដើមហេតុ ដែលនាំឲ្យបុរសនេះ រត់ចូលមកក្នុងផ្ទះរបស់លោកយ៉ាងប្រញាប់ដូច្នេះ ។

បុរសនឹកថាមុខតែខ្លួនស្លាប់ហើយ, រួចក៏រៀបរាប់ប្រាប់មហាសេដ្ឋី តាមដំណើររតាំងពីដើមដល់ចុងឥតបន្ទោះកន្លែងណាមួយ ។

រីឯបុត្ររបស់លោកមហាសេដ្ឋីស្តាប់បុរសនិយាយផង ក្អកល្អួច មើលផង ។

លុះបុរសនិយាយចប់ហើយ លោកមហាសេដ្ឋីមានចិត្តមេត្តាជាពន់ពេក ហើយបានហៅបុរសនេះឲ្យចូលមកបរិភោគបាយជាមួយដូចគ្រួមញាតិរបស់លោក ។ ព្រោះសេចក្ដីទៀយហត់នឹងសេចក្ដីខ្លាចស្លាប់ពន់ពេក បុរសមិនចាំបាច់ឲ្យគេហៅយូរ ចូលបរិភោគជាមួយភ្លាមទៅ ។

ចំណែកខាងពួកកងត្រវែល លុះកាលណាបានឃើញបុរសនេះរត់យ៉ាងលឿនដូច្នោះ នឹកស្មានថាជាចោរលួចតកើនផ្ទះគេ ក៏នាំគ្នាដេញតាមចិតតបង្គង់ទៀយ ។ ប៉ុន្តែបិតារបស់ស្ត្រីដែលមានសតិរឹងជាងគេ ហើយដែលមានគំនិតមួយលាក់ទុកក្នុងខ្លួនផង ក៏បាននិយាយកាន់ទៅពួកកងត្រវែលថា "តើលោកមកនេះមានការអ្វីនៅទីនេះ មានអ៊ែខ្ញុំ, កូនស្រីខ្ញុំនឹងកូនប្រសាខ្ញុំប៉ុណ្ណោះទេ ដូចលោកឃើញស្រាប់ហើយ, យើងទាំងអស់គ្នាកំពុងបរិភោគអាហារ, ប៉ុន្តែបើលោកស្មានថាមានចោររត់ចូលមកក្នុងផ្ទះរបស់ខ្ញុំ សូមលោកអញ្ជើញរកមើលចុះ", ថាហើយលោកមហាសេដ្ឋីក៏បើកឲ្យពួកកងត្រវែលឆែកឆេរផ្ទះរបស់លោកគ្រប់កន្លែង ។ លុះរកមើលសព្វគ្រប់ហើយ ពួកកងត្រវែលក៏សុំទោស រួចថយខ្លួនចេញអស់ទៅ ។ ឯបុរសក៏បានរួចខ្លួនក្នុងពេលនោះ ។

លុះកាលណាផុតអំពីរឿងដ៏លំបាកនេះហើយ មហាសេដ្ឋីអង្គុយលួចមើលមុខបុរស ឃើញកិរិយានឹងមារយាទល្អទៀងៗ ក៏ដំនុំនឹងកិរិយារបស់លោក សម្រេចឲ្យបុត្រីទៅបុរសនោះទៅ ។

ក្នុងពេលនោះ បុត្រីរបស់ព្រះមហាក្សត្រទ្រង់អាពាធជាទម្ងន់ ដោយសេចក្ដីនឹករលឹកដល់បុរស ។ រាល់ថ្ងៃព្រះនាងនៅសន្ទឹកសន្ធៃស្រពោនស្រពន់ នាំឲ្យលោកគ្រូពេទ្យទាំងប៉ុន្មានព្រួយចិត្តពន់ពេក ។ ព្រះមហាក្សត្រទាល់គំនិតក៏ធ្វើមិនដឹងខ្លួន ស្ដេចទៅសួរព្រះរាជបុត្រីឲ្យព្រះនាងមានបន្ទូលដោយត្រង់តាមទំនងហេតុដែលនាំឲ្យកើតទុក្ខឈឺទាំងខ្លួននេះ ។ ព្រះនាងក៏បានទូលព្រះបិតាតាមដំណើរ ហើយអង្វរព្រះអង្គឲ្យរកបុរសដែលព្រះនាងស្រឡាញ់ពេញចិត្តនេះឲ្យឃើញវិញ ។

ឯព្រះមហាក្សត្រដោយសារសេចក្ដីស្រឡាញ់បុត្រីពេក ក៏ភ្លេចសេចក្ដីក្រេវក្រោធ ហើយបានទាំងចាត់ចែងឲ្យអស់ពលរេហ៍រកបុរសវិញគ្រប់ដំបន់ផង ។ មួយទៀតស្ដេចបានតាំងព្រះទ័យថា ទ្រង់នឹងលើកលែងទោសឲ្យបុរសនោះថែមទៀត ។ ប៉ុន្តែបុរសនោះគេរកមិនឃើញសោះ ។ ក្រោយមកព្រះអង្គទ្រង់ធ្វើឧបាយមួយ គឺធ្វើបុណ្យយ៉ាងធំក្នុងព្រះរាជវាំង ហើយស្ដេចទ្រង់បង្គាប់ឲ្យអស់នាហ្មឺនមុខមន្ត្រីឲ្យចូលមកមើលបុណ្យនោះ ដោយខានមិនបានទាំងក្រុមញាតិរៀងរាល់គ្នាផង ។

អាស្រ័យហេតុនេះក្នុងទីក្រុងនោះគ្មានអ្នកណាមួយខានឡើយ ។ បណ្ដាពួកអ្នកទៅមើលបុណ្យ បុរសនឹងភរិយាក៏បានទៅមើលដែរ ។ ឯព្រះរាជបុត្រីដែលចាំសំឡឹងមើលមិនដាក់ព្រះនេត្រក៏ស្រែកឡើងថា "នុះប្ដីខ្ញុំ" ។ ក្នុងពេលនោះ មានស្រីម្នាក់ទៀតស្លៀកពាក់ស្អាតបាតចេញអំពីចំណោមមកប្រកែកជាមួយព្រះរាជបុត្រីផង, នាងនេះជាភរិយាដើមរបស់បុរសដែលបានគ្នាកាលមុនពស់ចឹក, នាងនិយាយថា "ខ្ញុំសូមបញ្ជាក់ថា បុរសនេះជាប្ដីខ្ញុំបានរៀបការពេញច្បាប់, កាលដែលពស់ចឹកគាត់ស្លាប់ទៅនោះ ខ្ញុំបានយករូបគាត់ទៅចងនៅលើក្បូនមួយតាមពាក្យរបស់គាត់ រួចខ្ញុំបណ្ដែតក្បូននោះទៅតាមទឹកទៅ, ឥឡូវនេះដោយសារបុណ្យព្រេងអស្ចារ្យនេះគាត់រស់ឡើងវិញ ខ្ញុំសូមប្រកាសថាគាត់ជាប្ដីខ្ញុំទេ" ។

ដោយសារនាងនិយាយយ៉ាងច្បាស់លាស់យ៉ាងនេះ បណ្ដាជនដែលចាំស្ដាប់នោះក៏ចូលចិត្តពលគ្នា ។ ប៉ុន្តែស្រីពីរនាក់ទៀតមិនចង់និយាយឲ្យវែងឆ្ងាយឡើយ ។ ការទាស់ប្រកែកគ្នានេះក៏ផុតរលត់ត្រឹមនោះទៅ ។ ឯព្រះមហាក្សត្រមិនព្រមកាត់សេចក្ដីនេះ ព្រោះព្រះអង្គសព្វព្រះទ័យលើព្រះរាជបុត្រីក្រៃពេក ព្រះអង្គខ្លាចល្អៀងនឹងសេចក្ដីយុត្តិធម៌ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យស្រីទាំងពីរអង្គទៅទូលដល់ព្រះនាងធត្តិយានីធូដាម្នាសារី (Thoudamna sari) ដែលមានប្រាជ្ញាល្បីល្បាញជាខ្លាំងនោះ ។

គ្រាន់តែឮឈ្មោះមួយនេះ ការទាស់ទែងក៏បាត់ស្ងាត់ទៅ ។ គឺថាស្រីទាំង ៣ នាក់ព្រមព្រៀងតាមព្រះរាជត្រាស់ ហើយនាំគ្នាត្រសុងទៅកាន់ប្រាសាទមួយដែលសង់នៅជិតទីក្រុងនោះ ។

ឯព្រះនាងខត្តិយានីក៏តាំងសាកសួររឿងនេះ តាំងពីដើមដល់ចុង គ្មានបន្ទោះកន្លែងណាមួយឡើយ ។

នាងប្រពន្ធដើមលុះនិយាយអំពីរឿងក្បូន រួចថា "បើប្តីខ្ញុំមិនស្លាប់យ៉ាងនេះឲ្យខ្ញុំហៅគាត់ម្តេចបាន" ។

ឯព្រះរាជបុត្រីនៃស្ដេច ដែលមានព្រះនេត្រថ្វាយង់ក៏តាំងមានព្រះបន្ទូលហូរដូចទឹកថា "ដោយសារសិល្បសាស្ត្រគុណៈមួយខ្ញុំមិនស្គាល់ឈ្មោះ ឯបុរសនេះកាលពីមុនក្លាយខ្លួនជាសត្វស្លាប ។ ពួកព្រានព្រៃក៏បានចាប់សត្វនោះយកមកថ្វាយព្រះបិតាខ្ញុំ ។ មានតែសេចក្តីស្លាប់ទេដែលនៅចាំគាត់ ។ ខ្ញុំបានជួយជីវិតគាត់ដោយបានយកគាត់មកទុកជិតខ្លួនដរាប ។ ខ្ញុំបានដឹងការណ៍អាថ៌កំបាំងរបស់គាត់ រួចខ្ញុំស្រឡាញ់គាត់ទៅ ។ ខ្ញុំស្រឡាញ់នេះគឺស្រឡាញ់ណាស់គ្មានរបស់អ្វីប្រៀបបានឡើយ ទាល់តែដល់ពេលដែលបិតាខ្ញុំបើកអង្ក្រែតរកចាប់ ។ គាត់ក៏ភ័យខ្លាំងពេក គាត់រត់ទាល់តែដាច់ខ្សែសិល្បក្លាយខ្លួនជាមនុស្សទៅ ។ ខ្ញុំមានចិត្តនឹកគាត់ស្ទើរស្លាប់ខ្លួន ។ ខ្ញុំក៏បាននិយាយត្រង់ប្រាប់ព្រះបិតាខ្ញុំ ។ ឯព្រះបិតាក៏ទ្រង់ប្រោសឲ្យគេរកទាល់តែឃើញគាត់មកវិញនេះ ហេតុដូច្នេះ គាត់គង់ជីវិត

នេះដោយសារខ្ញុំនៅស្ងៀម ។ ថ្ងៃនេះព្រះបិតាខ្ញុំទ្រង់លើកលែងទោសឲ្យគាត់ទាំងអស់ដោយសារខ្ញុំអង្វរព្រះអង្គពេក ។ ឯស្តេចក៏មានព្រះហឫទ័យសន្តោសចង់ឲ្យខ្ញុំនឹងគាត់បានគ្នាជាប្តីប្រពន្ធដែរ ។ ឱព្រះនាង! បើយ៉ាងនេះគាត់ត្រូវព្រាត់ប្រាសពីខ្ញុំវិញឬយ៉ាងណា?" ។

ចំណែកខាងកូនស្រីមហាសេដ្ឋី គ្រាន់តែនិយាយថា "លុះកាលណារត់ផុតពីកំពង់ហើយ បុរសនេះមានគ្រោះថ្នាក់ដល់ស្លាប់ខ្លួន ព្រោះពួកកងក្រវែលដេញតាមជាប់ពីក្រោយ ។ គាត់ភិតភ័យតក់ស្លុតជាខ្លាំងណាស់ ហើយរត់ចូលមកក្នុងផ្ទះរបស់ខ្ញុំ ។ ឯឪពុកម្តាយរបស់ខ្ញុំក៏បានជួយយោងជីវិតដោយបានប្រើមធ្យោបាយមួយប្រពៃណាស់ រួចលោកបានរៀបការខ្ញុំឲ្យទៅបុរសនេះទៅ ។ ហេតុយ៉ាងនេះ គាត់នឹងត្រឡប់ទៅជាមិនមែនប្តីរបស់ខ្ញុំវិញឬយ៉ាងណា?" ។

ព្រះនាងខត្តិយានីធូដាម៉ាសារី លុះគិតយូរបន្តិចទ្រង់មានព្រះបន្ទូលថា "ព្រះនាង! អស់ទាំងនាង! ចូរចាំស្តាប់សេចក្តីនេះ ខ្ញុំនឹងកាត់ឥឡូវនេះ" ។ រួចអ្នកទាំងអស់គ្នាក៏ឱនក្បាលចាំស្តាប់ ។

ព្រះនាងថា "នាងភរិយាទី ១ បានចងបុរសទៅលើក្បូន ហើយបានបណ្តែតចោលទៅតាមទឹក ។ ធ្វើយ៉ាងនេះក៏ដូចគ្នានឹងយករូបបុរសនោះទៅបូជាឬទៅកប់ក្នុងព្រះធរណីដែរ ។ ប៉ុន្តែថ្ងៃនេះអស្ចារ្យណាស់ បុរសនេះរស់ឡើងវិញ ។ ឯនាងគ្មានច្បាប់អ្វីនឹងបានបុរសនេះវិញទេ ។

ឯចំណែកខាងបុត្ររបស់ស្តេច បើសិនណាពួកកងត្រវែលចាប់បាន, គ្មានទឹកភ្លែកឯណា គ្មានសេចក្តីមេត្តាឯណា គ្មានពាក្យអង្វរឯណា គ្មានមុទុតាចិត្តឯណា អាចទប់នឹងការពិរោធស្តេចបានឡើយ នាងមុខជាខានជួបនឹងបុរសនេះរហូតមិនខាន ។ អាស្រ័យហេតុនេះ នាងគ្មានច្បាប់ត្រូវបានបុរសនេះវិញឡើយ ។ ពីព្រោះបុរសនេះមុខតែពីស្លាប់ បើសិនណាមាតាបិតារបស់នាងដែលត្រូវជាប្រពន្ធគេសព្វថ្ងៃនេះ មិនបានជួយដោយបានប្រើគំរិះនឹងឧបាយទាំងប៉ុន្មាននោះ ។ បើដូច្នេះគឺរូបនាងក្រោយបង្អស់នេះទេ ដែលត្រូវបានបុរសនេះដោយពេញច្បាប់ ។ សូមឲ្យនាងបានសុខជាមួយគ្នាដល់ផុតជីវិតរៀងខ្លួនទៅហោង" ។

លុះព្រះនាងខត្តិយានីមានព្រះបន្ទូលរួចហើយ អ្នកទាំងអស់គ្នាក្សាលសុខចិត្តរៀងខ្លួន ។

សុភានិងសង្ស្រារទាំងឡាយ ! អ្នកគោងមើលរឿងនេះឲ្យជាក់ ។

(មានត)

## លុះតែមានគុណធម៌ ២ ប្រការក្នុងចិត្ត :

១ – សេចក្តីស្នេហាចំពោះមាតុភូមិ

២ – សេចក្តីព្យាយាមដោយមិនខ្លាចស្លាប់

## ទើបរក្សាស្វ័យភាពបាន ។

យូរ.- អ៊ុន

រឿងសាមកុក

កណ្ឌទី ៣

## អ្នកឧកញ៉ាវិបុលរាជសេនា នូ - កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

អង់អ៊ុនតបថា ខ្លួនអ្នកជាសែលី តាំងតុះជាសែតាំង នឹងរាប់ថាជាអាពុកកូនយ៉ាងម្ដេច, បើតាំងតុះរាប់អានអ្នកជាកូនប្រាកដ ចុះកាលកាន់ខ្លួនដេញកាប់នោះ តើនឹកថាជាកូនដែរឬទេ? ដែលអ្នកនឹងខ្លាចគេនិន្ទានោះមិនគួរទេ ។ លីប៉ោ បានស្ដាប់ស្រាប់តែភ្ញាក់គំនិតគិតឃើញឡើង ទើបឆ្លើយតបថា សេចក្ដីខនេះក៏បានតែលោករំលឹកទាន់ ខ្ញុំគ្មានដីវ័ននឹងគិតឃើញសោះ ។

អង់អ៊ុនគិតឃើញថា លីប៉ោ ប្រាកដជាប្រែចិត្តចេញពីតាំងតុះពិតណាស់ ក៏ដាស់សតិលីប៉ោថា សព្វថ្ងៃនេះតាំងតុះជាសត្រូវនឹងរាជសម្បត្តិ អ្នកក៏ល្មមដឹងច្បាស់ប្រាកដក្នុងចិត្តហើយ, ដែលអ្នកបានមកនៅធ្វើរាជការ

ជាមួយនឹងគាំងតុះនេះ ក៏មានសេចក្ដីគាប់ប្រសើរជាច្រើនដង តើគាំងតុះបានឲ្យបំណាច់រង្វាន់ឡើងយសស័ក្ដិជានាហ៊្មឺនតំណែងអ្វីខ្លះដែរឬទេ? បើអ្នកតាំងចិត្តសុចរិតត្រង់នឹងព្រះមហាក្សត្រជាម្ចាស់ផែនដីវិញ សូម្បីអ្នកនឹងយកចិត្តទុកដាក់ជួយទំនុកបំរុងផែនដីតែម្ដង គឺកំចាត់ពួកសត្រូវរាជ-សម្បត្តិចេញបាន អ្នកនឹងឡើងទៅជានាហ៊្មឺនធំមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ឧត្ដមជាប់គង់ព្រះរាជពង្សាវតារតទៅ ។

លីហ៊ោបានឮដូច្នោះ ក៏លុតជង្គង់គំនាប់អង់អ៊ុនហើយថា ខ្ញុំបាទនឹងសូមយកអាសាផែនដីសងសឹកសម្លាប់អាតាំងតុះចេញឲ្យបាន លោកកុំមានសេចក្ដីសង្ស័យនឹងខ្ញុំបាទឡើយ ។ អង់អ៊ុនតបថា អ្នកគិតទំនុកបំរុងដល់ផែនដីដូច្នេះ ក៏ជាការគាប់ប្រសើរហើយ តែក្រែងអ្នកនឹងខ្ញុំគិតរួមគំនិតគ្នាទៅមិនបានយូរ បែរជានាំគ្នាស្លាប់ចោលបង់ទៀតទៅវិញទេដឹង ! ។ លីហ៊ោទាញយកគ្រួមកចាក់កដៃ សម្រក់លោហិតដាក់ក្នុងពែងស្រា ហើយស្បថស្បានថា "បើខ្ញុំមិនបានសម្លាប់តាំងតុះចេញដូចពាក្យថានេះទេ សូមឲ្យទេវតាបណ្ដាលឲ្យអាវុធផ្សេងៗ ប្រហារខ្លួនខ្ញុំបាទឲ្យវិនាសចុះ" ហើយលើកពែងស្រានោះផឹកអស់ទៅ ។ អង់អ៊ុនឃើញដូច្នោះក៏ក្រោកឡើងគំនាប់លីហ៊ោហើយថា ពេលនេះព្រះមហាក្សត្រនឹងអាណាប្រជារាស្ត្របានសេចក្ដីសុខក្សេមក្សាន្តព្រោះសតិប្បញ្ញារបស់អ្នក បើអ្នកនឹងចាប់ផ្ដើមធ្វើការនេះវេលាណា ខ្ញុំនឹងពន្យល់ឲ្យដឹង ។ លីហ៊ោក៏លាអង់អ៊ុនត្រឡប់ទៅផ្ទះវិញ ។

ចំណែកអង់អ៊ីនបង្គាប់ឲ្យហៅស៊ុនស៊ុយនឹងអ៊ុយអ៊ួនដែលជាទីប្រឹក្សាមកប្រាប់ហេតុ ដែលបានគិតនឹងលីប៉ោឲ្យសម្លាប់តាំងតុះ ។ អ៊ុយអ៊ួនជំរាបថា ព្រះចៅហៀនគេទ្រង់ព្រះឈ្មួននោះ តាំងតុះក៏បានដឹងច្បាស់ដែរ តែឥឡូវព្រះអាពាធធូរស្រាលបាន ២ ថ្ងៃហើយ តាំងតុះមិនទាន់បានដឹងដំណឹងនេះទេ បើដូច្នេះសូមលោករកអ្នកមានសតិប្បញ្ញាទៅអញ្ជើញតាំងតុះថា " មានព្រះរាជឱង្ការឲ្យហៅទៅគាល់នឹងបានប្រឹក្សារាជការជាធំ ", ហើយឲ្យតែងសំបុត្រសម្ងាត់ទៅឲ្យលីប៉ោ ជាសេចក្ដីព្រះតម្រាស់ ឲ្យលីប៉ោលើកទាហានទៅបង្កប់នៅទីស្ដេចចេញ បើតាំងតុះចូលមក ឲ្យមានសញ្ញាគ្នា ទើបការដែលគិតនោះនឹងធ្វើបានដោយស្រួល ។ ស៊ុនស៊ុយឆ្លើយថា ដែលគិតដូច្នេះក៏ត្រូវហើយ តែនឹងរកនរណាជាបំរើកាន់សំបុត្រព្រះតម្រាស់ចេញទៅដល់តាំងតុះនោះ? ។ អ៊ុយអ៊ួនតបថា លីស៊ុកធ្វើរាជការមានសេចក្ដីគាប់ប្រសើរល្អ តាំងតុះមិនបានពិតទូលឲ្យឡើងយសស័ក្តិឡើយ លីស៊ុកក៏មានសេចក្ដីទោមនស្សត្រូវចិត្តពន់ពេក បើឲ្យលីស៊ុកកាន់ព្រះតម្រាស់ទៅឲ្យ ប្រហែលតាំងតុះមិនមានសេចក្ដីសង្ស័យ ។ អង់អ៊ីនក៏យល់ព្រមតាមពាក្យលីស៊ុក ហើយឲ្យហៅលីប៉ោទៅជួប ហើយប្រាប់សេចក្ដីដែលប្រឹក្សាគ្នានោះឲ្យស្ដាប់គ្រប់ប្រការ ។ លីប៉ោយល់ព្រមហើយនិយាយថា លីស៊ុកនោះបានទៅនិយាយល្បួងបញ្ចុះបញ្ចូលខ្ញុំបាទកាលដែលនៅធ្វើការជាមួយគ្នានឹងតេងង៉ួន បើលីស៊ុក

មិនព្រមទៅ ហើយបែកការដែលយើងគិតនេះទៅថ្ងៃមុខ ខ្ញុំនឹងធានាសម្លាប់លីសុកចេញ ។ អង់អ៊ុននឹងលីប៉ោបង្គាប់ឲ្យទៅហៅលីសុកមកជួប ហើយលីប៉ោនិយាយថា កាលដែលខ្ញុំនៅទីងតេងង៉ួននោះ អ្នកបានទៅ-ល្បួងបញ្ចុះបញ្ចូលខ្ញុំ ។ សម្លាប់តេងង៉ួនយកក្បាលមកឲ្យតាំងតុ: ឥឡូវនេះខ្ញុំឃើញតាំងតុ:ធ្វើការអាក្រក់ក្បថផែនដី ទើបព្រមព្រៀងគ្នាគិតរំលាងតាំងតុ:ចេញវេលានេះ យើងត្រូវការប្រើអ្នកឲ្យកាន់ព្រះតម្រាស់ទៅហៅតាំងតុ:ឲ្យចូលមកគាល់ ហើយយើងនឹងសម្លាប់តាំងតុ:ចេញ តើអ្នកនឹងព្រមទៅឬមិនទៅ? ។

លីសុកបានស្តាប់ហើយឆ្លើយតបថា សព្វថ្ងៃនេះខ្ញុំគិតរកឧបាយនឹងសម្លាប់តាំងតុ:ជាដរាប តែថាខ្ញុំនៅអារម្ភព្រោះអ្នកជារូប ១ ចិត្ត ១ នឹងតាំងតុ: ទើបគិតធ្វើការនោះមិនបានសម្រេច ឥឡូវបើអ្នកប្រាកដជាប្រើខ្ញុំទៅហៅតាំងតុ:ឲ្យចូលមកគាល់ដោយឧបាយមែន ខ្ញុំមានសេចក្តីពេញចិត្តណាស់ សុំទទួលយកអាសាទៅហៅតាំងតុ:ឲ្យចូលមកបាន ។ ពេលនោះលីសុកយកព្រួញធ្នូមកកាច់ជា ២ កំណាត់ ហើយស្បថស្បាទតម្រង់ខ្លួនថា បើខ្ញុំមិនបានធ្វើតាមពាក្យប្តេជ្ញានេះទេ នឹងត្រឡប់នាំសេចក្តីនេះទៅបំបែកឲ្យតាំងតុ:ដឹងការណ៍វិញនោះ សូមឲ្យខ្លួនខ្ញុំដាច់ទៅជា ២ កំណាត់ដូចព្រួញដែលកាច់នេះចុះ ។ អង់អ៊ុនបានស្តាប់លីសុកនិយាយដូច្នោះគំអស់សេចក្តីសង្ស័យ ហើយបែរជាមានសេចក្តីត្រេកអរជាពន្លឹក ទើប-

ក្រោកឡើងគំនាប់លីសុកហើយថា អ្នកតាំងចិត្តសុចរិតត្រង់នឹងផែនដី ដូច្នេះ បើសម្រេចសេចក្តីប្រាថ្នាកាលណា អ្នកនឹងបានជានាហ្មឺនធំតទៅ ។

លុះដល់ព្រឹកឡើង អង់អ៊ុនតែងសំបុត្រព្រះតម្រាស់ ហើយឲ្យកេណ្ឌទាហានសេះ ២០ ប្រគល់ឲ្យលីសុកៗ ក៏ចេញទៅដល់ទីក្រុងថ្មី, ទាហានម្នាក់នាំយកសេចក្តីជំរាបតាំងគុៈៗ បានដឹងចេញមកទទួលព្រះតម្រាស់ ហើយនាំលីសុកចូលទៅក្នុងក្រុងថ្មី ។ លីសុកជំរាបតាំងគុៈថា ឥឡូវនេះព្រះចៅហៀនតេទ្រង់ព្រះឈួនជាទម្ងន់ នឹងរកអ្នកឯណានិយាយការរាជការគ្មាន នាហ្មឺនទាំងពួងប្រែក្បាគ្នាយល់ព្រមឲ្យមកអញ្ជើញមហាឧបរាជចូលទៅនឹងប្រគល់ជូនរាជសម្បត្តិ ។ តាំងគុៈសួរលីសុកថា ដែលនាហ្មឺនទាំងពួងប្រែក្បាគ្នាដូច្នេះ អ្នកបានឮអង់អ៊ុននិយាយដូចម្តេចខ្លះ ។ លីសុកឆ្លើយថា ដែលនឹងប្រគល់រាជការទៅរាជសម្បត្តិជូនដល់លោកនេះ អង់អ៊ុនជាដើមគំនិតស្នើនឹងមន្ត្រីទាំងពួងៗ ក៏យល់ព្រម ឥឡូវនេះអង់អ៊ុនចាត់ចែងត្រាសម្រាប់រាជ្យទុកជូនលោកជាស្រេចហើយ ។ តាំងគុៈបានស្តាប់ដូច្នោះ ក៏មានចិត្តសោមនស្សហើយប្រាប់លីសុកថា កាលពីយប់មិញយើងមានសុបិននិមិត្តឃើញថា មានសត្វមករ ១ មករុំព័ទ្ធជុំវិញខ្លួនយើង ដល់ព្រឹកឡើងស្រាប់តែមានដំណឹងនេះមកដល់យើង បើដូច្នេះចាំយើងនឹងទៅស្រុកក្រុង ដែលអ្នកបានកាន់ព្រះតម្រាស់មកនេះ យើងក៏មានសេចក្តីត្រេកអរណាស់ហើយ បើបានរាជសម្បត្តិពិតប្រាកដ

មែន យើងនឹងតាំងអ្នកឲ្យធ្វើជានាហ្មឺនធំ គឺទីអគ្គមហាសេនា ។ លីសុក ធ្វើហាក់ដូចជាទទួលប្រសាសន៍តាំងតុៈជាប្រាកដណាស់ ទើបបង្គាប់ឲ្យ លីឈុយ គុយគី គៀវបេ នឹងហួនគៀវ កេណ្ឌកងសេនាទាហានបាន ៣ ពាន់ឲ្យទៅរក្សាក្រុងថ្មី ។ ឯតាំងតុៈចូលទៅរកមាតាហើយជំរាបថា ឥឡូវនេះខ្ញុំនឹងទៅទទួលរាជសម្បត្តិហើយ អ្នកម្តាយមុខជានឹងបានជា ហងថៃហ៊ូ គឺជាសម្តេចព្រះវររាជជននី ។ មាតាតបថា ខ្លួនម្តាយក៏ ចាស់ជរាអាយុដល់ ៩០ ឆ្នាំហើយ ម្តាយបានពឹងបុណ្យកូនក៏ល្មមបាន សេចក្តីសុខប៉ុណ្ណោះហើយ ពេលនេះមាតាមានសេចក្តីពិការក្នុងចិត្ត ណាស់ ព្រោះចេះតែកម្រើកញ័រខ្លួនទាំងសព្វាង្គកាយ ហើយក្នុងចិត្ត ក៏ចេះតែភ្ញាក់តក់ស្លុតមកជាច្រើនវេលាហើយ បើកូននឹងចូលទៅក្រុង នោះ ត្រូវគិតប្រយ័ត្នរាំងខ្លួនឲ្យល្អកុំធ្វេសប្រហែស ។

តាំងតុៈតបថា "ដែលអ្នកម្តាយមានអាពាធក្នុងខ្លួននោះ ព្រោះបុណ្យ កូននឹងដល់ហើយ បានជាបណ្តាលឲ្យកើតមានអាពាធដូច្នេះ" ហើយលា មាតាចូលទៅរកនាងគៀវសៀន ហើយនិយាយដំណាលសេចក្តីទាំងនោះ ឲ្យនាងស្តាប់ថា បើយើងបានគ្រងរាជសម្បត្តិវេលាណា យើងនឹងលើក នាងឲ្យធ្វើជាអគ្គមហេសីខាងឆ្វេង ។ នាងគៀវសៀនបានស្តាប់ក៏គិតឃើញ ថា ប្រហែលជានាហ្មឺនទាំងពួងឲ្យមកនិយាយដូច្នេះ ប្រាថ្នានឹងសម្លាប់ ភាំងតុៈជាប្រាកដ ។ នាងគៀវសៀនគំនាប់ហើយធ្វើជាអរពេះពយុ ។

តាំងតុះឲ្យរៀបចាត់ចែងសេនាទាហាន ហើយឡើងជិះរថលើកក្បួនហែ ចេញទៅតាមផ្លូវប្រមាណបាន ៣០ សិន ភ្លៅរថដែលតាំងតុះជិះនោះបាក់ដាច់ជា ២ ចំណែក, តាំងតុះឡើងជិះសេះតទៅទៀតបានប្រមាណ ១០០-សិន ស្រាប់តែសេះផ្អើលដាច់បង្ហៀរអំពីដៃ ។ តាំងតុះងាកមកសួរលីសុកថា ដែលបាក់ភ្លៅរថនឹងសេះផ្អើលដាច់បង្ហៀរដូច្នេះ អ្នកយល់ឃើញថាល្អឬអាក្រក់ប្រការម្តេច? ។ លីសុកជំរាបថា ដែលកើតហេតុទាំងពីរនេះ ជាបុព្វហេតុត្រូវមហាឧបាដនឹងបានគ្រងរាជសម្បត្តិ ហើយនឹងបានទ្រង់រថប្រដាប់ដោយគ្រឿងចម្លាក់របនា ព្រមទាំងសេះព្រះទីនាំង ។ តាំងតុះបានស្តាប់ក៏ជឿជាក់ក្នុងចិត្ត ព្រោះមិនបានដឹងកលឧបាយដោយប្រការផ្សេងៗ លុះទៅដល់ទ្វារក្រុង បណ្តានាហ៉ឺនតូច-ធំចេញទៅគំនាប់ទទួលតាំងតុះឈូរឆរ ។ ឯលីយូមានជម្ងឺឈឺមិនសប្បាយមិនបានចេញទៅទទួល ។ តាំងតុះក៏ចូលទៅក្នុងទីលំនៅរបស់ខ្លួន; ពេលនោះលីប៉ោក៏ឈរគំនាប់តាំងតុះៗនិយាយថា បើយើងបានរាជសម្បត្តិយើងនឹងតាំងអ្នកឲ្យធ្វើជាធំត្រួតសេនាទាហានទាំងអស់ ។ លីប៉ោធ្វើជាត្រេកអរទទួលពាក្យតាំងតុះ ហើយលាថយមកវិញ ។

លុះដល់ពេលយប់ក្នុងខែមិគសិរ ពួកកូនក្មេងអ្នកស្រុក ៣០ នាក់បបួលគ្នាទៅលេងមុខផ្ទះតាំងតុះ ហើយច្រៀងរាយទំនុកថា «ស្មៅទាំងអស់មានស្លឹកខៀវស្រស់ ដុះលេចឡើងមិនបានយូរប៉ុន្មាន ៩ ឬ ១០ ថ្ងៃ

ក៏នឹងស្លាប់" ។ តាំងគុះបានឮសំឡេងក្ងងព្រៀងដូចគេយំ ក៏សម្ងំចាំស្ដាប់ នឹកប្លែកក្នុងចិត្តណាស់ ទើបឲ្យហៅលីសុកទៅសួរថា ដែលក្ងងព្រៀងឮសំឡេងរហៀងដូចយំនេះតើ អ្នកនឹងយល់ឃើញប្រការម្ដេច? ។ លីសុកតបថា សំឡេងក្ងងដូច្នេះជាបុព្វនិមិត្តរបស់លោកធំវិសេសណាស់ ព្រោះសែឡេវនឹងសាបសូន្យហើយសែតាំងនឹងរុងរឿងតទៅ ។ តាំងគុះក៏មានសេចក្ដីត្រេកអរណាស់ លុះដល់ព្រឹកឡើងក៏តែងខ្លួនពេញយស ហើយឡើងរថនឹងចូលទៅក្នុងព្រះរាជវាំង ។

លុះទៅដល់កណ្ដាលផ្លូវ ទទួលជួបនឹងតួយិន ១ នោះពាក់អាវខៀវម្លូកស ដៃកាន់ឈើច្រត់ ហើយយកសំពត់ស្ដើងប្រវែង ៨ ហត្ថចងធ្វើទង់ មានអក្សរនៅដើមទង់ ១ តួថា "ទៅ" ចុងទង់ ១ តួថា "ទៅ" ទាំង ២ តួនោះផ្សំគ្នាហៅថា "លី" ប្រែថា "សែលី" ។ សំពត់សនោះភាសាចិនហៅថា "ប៉ោ" ។ ប្រស្នាដែលតួយិនធ្វើនេះបានសេចក្ដីថា លីប៉ោនឹងសម្លាប់តាំងគុះ ។ ឯតាំងគុះមិនយល់សេចក្ដីក្នុងប្រស្នានោះ ក៏មានសេចក្ដីសង្ស័យទើបសួរលីសុកថា ដែលតួយិនធ្វើដូច្នេះ តើអ្នកណានឹងយល់ឃើញដូចម្ដេច? ។ លីសុកដឹងច្បាស់ក្នុងប្រស្នាតែក្លែងប្រាប់តាំងគុះថា: 'តួយិនធ្វើដូច្នេះព្រោះខួបចរិតទេ នឹងកាន់យកថាល្អឬអាក្រក់នោះមិនបាន" ហើយលីសុកក៏ប្រើទាហានបណ្ដេញតួយិនចេញឆ្ងាយពីផ្លូវ ។ លុះតាំងគុះចូលទៅដល់ទ្វាររាំង, លីសុកប្រើឧបាយ ឲ្យតាំងគុះឃាត់

ទាហានរុកខាងក្រៅ, ហើយលីសុកនាំរថតាំងតុះចូលទៅក្នុងកំផាំងពីទីគាល់ ៗ តាំងតុះក្រឡេកឃើញនាហ៊ឺនកាន់គ្រឿងឈរជំរៀបគ្នា ក៏មានសេចក្តីភ័យបារម្ភ ហើយសួរលីសុកថា ហេតុដូចម្តេចបានជាពួកនាហ៊ឺនឈរកាន់គ្រឿងដូច្នេះ? ៗ លីសុកមិនបានតបសោះ បង្ខំឲ្យបររថចូលទៅក្នុងទីព្រះរាជពេងរម្យ ៗ

អង់អ៊ីនឃើញដូច្នោះ ក៏ស្រែកប្រកាសថា សត្រូវរាជសម្បត្តិមកដល់ហើយ ចុះទាហានយើងហេតុម្តេចក៏មិនពិឃាដបង់ទៅ? ៗ ឯទាហានដែលបង្កប់នៅទីនោះ ក៏ស្ទុះស្រែចេញមកយកកទ្ធួនចាក់តាំងតុះៗក៏ក្រាបនៅក្នុងរថ ហើយស្រែកហៅលីប៉ៅឲ្យជួយ ៗ លីប៉ៅស្ទុះចេញមកហើយស្រែកថា ខ្ញុំជាសត្រូវរាជសម្បត្តិ ហេតុម្តេចស្រែកឲ្យយើងជួយ" ថា ហើយក៏យកកទ្ធួនចាក់ត្រូវត្រង់កតាំងតុះធ្លាក់ពីលើរថស្លាប់ ៗ លីសុកក៏កាត់ក្បាលតាំងតុះហើយស្រែកប្រកាសថា អាសត្រូវរាជសម្បត្តិស្លាប់ហើយ ៗ បណ្តានាហ៊ឺនតូច ធំទាំងអស់ដល់បានឃើញដូច្នោះ ក៏មានចិត្តត្រេកអរគ្រប់គ្នា ៗ លីប៉ៅស្រែកថា ដែលតាំងតុះធ្វើការអាក្រក់ដូច្នេះព្រោះស្តាប់ពាក្យលីយូ នរណានឹងអាចយកអាសាទៅចាប់លីយូឲ្យយើងបាន ៗ លីសុកឆ្លើយទទួលយកអាសា ហើយក៏នាំទាហានទៅព័ទ្ធចាប់លីយូនឹងពួកបក្សបងប្អូនមកទាំងអស់ ៗ អង់អ៊ីនបង្គាប់ឲ្យនាំបុត្រភរិយានឹងបក្សពួកព្រមទាំងខ្លួនលីយូទៅសម្លាប់គ្មានសល់ ៗ សម័យនោះ

អាណាប្រជានុរាស្ត្រទាំងពួងក្នុងទីក្រុង ដែលមានចិត្តស្អប់តាំងតុះបបួលគ្នាទៅជេរប្រទេចខ្មោច ហើយយកដៃចង្អុលត្បុកក្បាលខ្លះ យកជើងធាក់ប្រឹខ្លះ ទាល់តែសពនោះខ្ទេចខ្ទីពុះពោះទៅ ។ អងអ៊ុនបានឲ្យនាំសពនោះទៅបោះចោលក្រៅព្រំខែត្រ ដោតក្បាលផ្កាលទុកត្រង់ផ្លូវបែកឲ្យមានមនុស្សនៅចាំរក្សា ។ ឯអ្នកចាំនោះវះពន្ទះយកសាច់សពតាំងតុះចេញ ហើយដាក់ប្រឆេះប្រេងក្នុងលលាដ៍ក្បាល យកភ្លើងអុជដុសតាងចង្កៀងរៀងរាល់ថ្ងៃទៅ ។

ចំណែកអងអ៊ុនឲ្យលីចៅ លីសុក ទឹងហាងហូគោ ទាំង ៣ នាយនេះលើកទាហាន ៤ មុឺន ទៅសម្លាប់បក្សពួកតាំងតុះឯស្រុកក្រុងថ្មីទាំងប្រុស ទាំងស្រីអស់គ្មានសល់ ហើយរឹបយកទ្រព្យរបស់នាំមកដាក់ឃ្លាំងៗ ឯលីឈុយ គុយគី ទៀវចេទឹងហ្វូនតៀវ ដែលតាំងតុះឲ្យនៅរក្សាស្រុកក្រុងថ្មី កាលដឹងសេចក្តីដូច្នោះហើយ ក៏នាំទាហាន ៣ ពាន់រត់ទៅនៅស្រុកសៀងសៃ ។

កាលលីចៅ លីសុក ហាងហូកោ សម្លាប់បក្សពួកតាំងតុះទឹងមាតាសាច់ញាតិអស់ហើយ លីចៅក៏ចូលទៅយកនាងតៀវសៀនមកទុកនឹងខ្លួន ។ ឯពួកស្រី ៨០០ នាក់ក៏ចាត់ឲ្យមាតាបិតានាំយកខ្លួនទាំងអស់ទៅវិញ ។ បណ្តាទ្រព្យរបស់ទាំងប៉ុន្មានក៏ឲ្យទាហានដឹកជញ្ជូនដាក់រទេះនាំទៅឲ្យអងអ៊ុនក្នុងទីក្រុង ។ អងអ៊ុនក៏យករបស់ទាំងនោះចែករំលែក

ឲ្យទាហានទាំងពួងតាមសមគួរ ហើយប្រជុំអស់នាហ្មឺនមុខមន្ត្រីតូចធំប្រឹក្សាថា "ឥឡូវនេះ សត្រូវរាជសម្បត្តិស្លាប់បាត់អស់ហើយ ផែនដីក៏បានសេចក្ដីសុខក្សេមក្សាន្ត យើងត្រូវបបួលគ្នាលេងឲ្យសប្បាយចុះ" ថាហើយចាត់ចែងរៀបលៀងភោជនាហារនាហ្មឺនទាំងពួង ។

ពេលនោះមានបំរើមកប្រាប់អង់អ៊ុនថា មាននាហ្មឺនម្នាក់ឈ្មោះសួយ៉ុង មកអង្គុយយំស្រណោះខ្មោចតាំងតុ: ។ អង់អ៊ុនខឹងណាស់ឲ្យទាហានទៅចាប់យកខ្លួនមកសួរពិចារណាថា ហេតុអ្វីខ្លួនជានាហ្មឺនក្នុងរាជការមកសោកាអាឡោះអាល័យតាំងតុ: ក្រែងខ្លួនចូលគំនិតនឹងតាំងតុ: ជាសត្រូវរាជសម្បត្តិឬ? ។ សួយ៉ុងគំនាប់ហើយឆ្លើយថា ខ្ញុំបាទនឹងបានចូលគំនិតដោយគិតខុសដូច្នោះក៏ទេ តែបានជាមកយំសោកស្រណោះនោះពីព្រោះនឹករលឹកដល់គុណតាំងតុ: ដែលបានយកខ្លួនខ្ញុំបាទមកធ្វើជានា-ហ្មឺនក្នុងរាជការ ទោសខ្ញុំបាទខុសត្រង់នេះសូមជីវិតនៅឲ្យរស់នឹងបានជួយធ្វើរាជការរក្សាផែនដីតទៅ ។ នាហ្មឺនទាំងពួងដែលបានស្គាល់ជាសួយ៉ុងទៀងត្រង់សុចរិត ក៏បបួលគ្នាសុំទោសទាំងអស់ ។ មាឃិតទុនខ្សឹបអង់អ៊ុនថា សួយ៉ុងនេះជាមនុស្សសុចរិតពិតត្រង់ណាស់ តំរេះប្រាជ្ញាក៏មានៗ មនុស្សរាប់អានស្រឡាញ់ក៏ច្រើន ទោសដែលល្មើសនោះ បើនឹងសម្លាប់ចេញក៏គួរ តែថាក្រែងបណ្ដារាស្ត្រនឹងមានពាក្យគរហានិន្ទា ។ អង់អ៊ុនតបថា ស្រុកទេសកើតចលាចលទើបនឹងស្ងប់រាបទាបក្នុងថ្ងៃនេះ ព្រះចៅ

ហៀនគេក៏នៅទ្រង់ព្រះកុមារណាស់ ទោះបីស្វយ៉ុងជាមនុស្សមានសតិ-ប្បញ្ញាក៏ពិត តែខ្ញុំមិនត្រូវការនឹងយកឲ្យធ្វើជានាហ្មឺនទីប្រឹក្សាយើងបានទេ ដោយហេតុថា បើយើងនឹងបណ្ដោយឲ្យមនុស្សធ្វើល្មើសនឹងព្រះរាជ-សម្បត្តិហើយបេះតែលើកទោសទៅនោះ ច្បាប់សម្រាប់ផែនដីនឹងត្រឡប់ត្រឡិនខូចទៅ ៗ ម៉ាយិតបានឮដូច្នោះ ក៏ថយចេញទៅហើយនិយាយនឹងនាហ្មឺនទាំងពួងថា ធម្មតាផែនដីទីមួយៗបើមិនរកមនុស្សជាអ្នកមានសតិប្បញ្ញាទុកទេ ប្រទេសនោះក៏មិនឋិតថេរបេរកាលតទៅទៀតបាន ៗ

គ្រានោះ អង់អ៊ុនបង្គាប់ឲ្យចាប់យកខ្លួនស្វយ៉ុងទៅដាក់គុក ហើយលបបង្គាប់ឲ្យនាយកូឃុំដាក់ច្រវាក់ខ្នោះឃ្នាបរឹតរួតត្រាតែស្លាប់ ៗ បណ្ដានាហ្មឺនទាំងអស់ដែលបានដឹងថាស្វយ៉ុងស្លាប់ហើយក៏មានសេចក្ដីបរិទេវនាការគ្រប់គ្នា ៗ

(មានត)

រស់ដូចស្លាប់

**បើមាតុប្រទេសធ្លាក់ចុះទៅកាន់ទាសភាព**
**តើយើងដែលរស់នៅមានប្រយោជន៍អ្វី?**

យូរ-អ៊ុន

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

## សម័យនគរធំ

អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

---

ព្រះអង្គមានព្រះអគ្គមហេសី ព្រះនាមដូចម្ដេចមិនប្រាកដ, ប្រាកដតែថា ព្រះអង្គមានព្រះរាជធីតាច្បង ១ អង្គ ព្រះនាម "នរេន្ទ្រលក្ស្មី" មានព្រះរាជស្វាមីព្រះនាម "ក្សត្រិន្ទ្រាទិត្យ" ត្រូវជាព្រះអនុជនៃព្រះហិរណ្យវរ្ម័ន ។ មានព្រះរាជឱរស ១ អង្គព្រះនាមព្រះមហេន្ទ្រាទិត្យ ។ មានព្រះរាជជាយាព្រះនាម "រាជបតិន្ទ្រលក្ស្មី" តែមិនបានដឹងច្បាស់ថា ជាធីតាក្សត្រិយ៍អង្គណាទេ ។

**មានបញ្ហាថាៈ** — ព្រះធរណេន្ទ្រវរ្ម័ន ជាព្រះជេដ្ឋា គួរតែបានសោយរាជសម្បត្តិមុនព្រះបាទជយវរ្ម័ន ដ៏ជាព្រះអនុជ, នេះហេតុម្ដេចព្រះអនុជបានសោយរាជ្យមុនព្រះរៀមទៅវិញ? ។ មានបរិហារថាៈ ការសោយរាជ្យរបស់ព្រះបាទជយវរ្ម័នទី ៦ នោះ មិនបានប្រព្រឹត្តទៅតាមលំដាប់នៃច្បាប់រាជសន្តតិវង្សទេ គឺក្នុងពេលនោះ មានការណ៍បះបោរក្នុងនគរ, ព្រះបាទជយវរ្ម័នទី ៦ ស្ដេចចេញក្រាបទាល់តែកបទាបទៅវិញ, ដូច្នេះរាជសម្បត្តិទើបបានទៅព្រះអង្គដូចពោលមក, កាលទ្រង់សោយ

ទិវង្គតហើយ គ្មានព្រះរាជឱរសនឹងទទួលរាជសម្បត្តិស្នង គេទើបអញ្ជើញព្រះជេដ្ឋាធិរាជដែលជាព្រះរាជវង្សជាន់ខ្ពស់ ឲ្យទទួលគ្រងរាជសម្បត្តិតមកៗ

**ការផែនដី** :– ព្រះបាទធរណេន្ទ្រវរ័ន្ទទី ១ ទ្រង់ទទួលគ្រងរាជសម្បត្តិក្នុងវ័យជរាណាស់ទៅហើយ ៗ តាមប្រក្រតីអំពីដើមមក ទ្រង់មានកិរិយាសុភាពជាសប្បុរស សព្វព្រះរាជហឫទ័យនិពន្ធពាក្យកាព្យ តែពាក្យកាព្យរបស់ព្រះអង្គទាំងប៉ុន្មាននោះ មិនបានប្រាកដមាននៅមកដល់វេលានេះទេ ៗ មកក្នុងបច្ឆិមវ័យនេះព្រះរាជហឫទ័យរបស់ព្រះអង្គដេកដួលទៅតែក្នុងផ្លូវធម៌ ៗ ការផែនដី ទ្រង់គ្រាន់តែថ្ងូបទុក មិនឲ្យលិចលង់ទៅហួសពេក, ការកសាងរបស់សំខាន់ៗ ដែលព្រះមហាក្សត្រិយ៍មុនៗ ធ្លាប់ធ្វើមក នឹងការកម្រាបពួកបះបោរនៅតាមបច្ចន្តរដ្ឋ ដូចយ៉ាងពួកថៃតាំងឥស្សរភាពនៅយានកជៀងសែននោះ ទ្រង់មិនបានសំដែងស្នាព្រះហស្តទុកទេ ប្រាកដតែថា ទ្រង់បានបន្ធូរបន្ថយដំឡៃមុខពន្ធដារក្នុងព្រះនគរឲ្យតិចចុះ ជាហេតុឲ្យធូរស្រាលដល់បណ្តាពស្រ្តអ្នកត្រូវបង់ពន្ធ ដោយអំណាចសេចក្តីសប្បុរសរបស់ព្រះអង្គ ៗ

ព្រះបាទធរណេន្ទ្រវរ័ន្ទទី ១ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបានតែត្រឹម ៥ ឆ្នាំក៏ស្តេចសោយទិវង្គតទៅតាមយថាកម្ម, រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទបរមនិស្កលបទ" ៗ

## ព្រះចាន់ស្សរាជ ទី ២

### ព. ស. ១៦៥៦ - ១៦៥៨, គ. ស. ១១១៣ - ១១៤៥ (១)

ព្រះមហាក្សត្រិយ៍អង្គនេះ ជាព្រះឱរសព្រះក្សត្រិន្រ្ទាទិត្យ (ដែលជាប់តំណវង្សមកអំពីព្រះហិរណ្យវរ្ម័ន) នឹងព្រះនាងនរេន្រ្ទលក្ស៊ី (ដ៏ជាព្រះរាជធីតាព្រះបាទធរណេន្រ្ទវរ្ម័នទី ១), ទ្រង់មានព្រះរូបឆោមល្អ ជាមជ្ឈិមបុរស ព្រះបរមរូបរបស់ព្រះអង្គ គេបានសាងទុកនៅព្រះវេៀង ប្រាសាទនគរវត្តបែកខាងត្បូង នៅដល់សព្វថ្ងៃនេះ ។

ក្រោយដែលព្រះបាទធរណេន្រ្ទវរ្ម័នទី ១ សោយទិវង្គតហើយ ប្រទេសកម្ពុជាបែកជា ២ ដោយមានព្រះរាជវង្ស ២ អង្គ ឬ ២ ពួក រំពាទដណ្តើមរាជសម្បត្តិគ្នា តែមិនប្រាកដព្រះនាមដូចម្តេច ។ គ្រានោះព្រះស្សរាជ ទ្រង់នៅក្នុងបឋមវ័យ (កំឡោះ) តែជាអ្នកមានព្រះប្រីជាឆ្លាតវាងវៃ ទ្រង់យល់ហេតុផលបានវែងឆ្ងាយ ទ្រង់ព្រះចិន្តាថា បើនឹងបណ្តោយឲ្យសង្រ្គាមកើតនៅក្នុងព្រះនគរដូច្នេះទៅ មិនយូរប៉ុន្មានទេមុខជានឹងមានប្រទេសដទៃ ដែលមានឥទ្ធិពលដូចយ៉ាងចាម្ប៉ាជាដើម លើកទ័ពមកសង្រ្គ្រាបយកផ្ទួនទៀតជាមិនខាន ដូចដែលធ្លាប់ប្រាកដមានក្នុងប្រវត្តិសាស្ត្រមុនៗ នេះមកហើយ ។ លំដាប់នោះ ព្រះអង្គក៏រួបរួមកងទ័ពមួយ

---

១ សាស្ត្រាចារ្យ ហ្សក ស៊ីដេស សរសេរថា ព្រះមហាក្សត្រិយ៍អង្គនេះ សោយរាជ្យពីក្នុងឆ្នាំ ១១១៣ ដល់ ១១៥០ រួមជា ៥១ ឆ្នាំ ។

ផ្នែកទៀតជាពួកទី ៣ នៅកំមណ្ឌរៈ ហើយទ្រង់លើកទៅវាយក្សត្រិយ៍អ្នកបះបោរទាំង ២ ពួក ទាល់តែបរាជ័យរកបទៅ ទើបទ្រង់ឡើងគ្រងពិភពផែនដីតមក មានព្រះបរមនាមថា "សូរ្យវ័ន្ត" ឬ "ស្រីសូរ្យវ័ន្ត" រាប់ជាទី ២ ស្ដេចគង់នៅក្រុងស្រីយសោធរបុរៈ ។ ព្រះអគ្គមហេសីប្រហែលជាទ្រង់មានដែរតាមរាជប្រវេណី តែព្រះនាមដូចម្ដេចមិនប្រាកដក្នុងប្រវត្តិសាស្ត្រ ។ ឯព្រះរាជឱរសព្រះរាជធីតាប្រហែលជាគ្មានទេ ទើបមិនប្រាកដក្នុងពេលដែលព្រះអង្គសោយទិវង្គត ។

**ការផែនដី:** – ព្រះបាទសូរ្យវ័ន្តក្រោយដែលទ្រង់បានឡើងគ្រងពិភពហើយក្នុងរវាង ៣ - ៤ ឆ្នាំនោះ ទ្រង់ក៏បានចាត់ការគ្រប់គ្រងផ្នែកមធ្យមរដ្ឋឲ្យបានរៀបរយតាមដើម និងទ្រង់ចាត់ការកសាងគ្រឿងអាវុធយុទ្ធភណ្ឌ និងបង្ហាត់សេនាទាហានទុកជាយ៉ាងច្រើនសម្រាប់ការពារប្រទេសកុំឲ្យមានការណ៍បះបោរដូចក្នុងរដ្ឋកាលមុនៗ នេះទៀត ។

និយាយពីពួកសៀមដែលមានព្រះព្រហ្មរាជជាប្រមុខនោះ មកក្នុងឆ្នាំ ព. ស. ១៦៦០ ប្រហែលជាគិតថា ព្រះបាទសូរ្យវ័ន្តទី ២ ដែលទើបសោយរាជ្យថ្មី គង់ទន់ខ្សោយបែបយ៉ាងព្រះបាទធរណិន្ទ្រវ័ន្តទី ១ ទើបរួបរួមទ័ពបានប្រហែល ៨០.០០០ នាក់ លើកចុះមកសង្កត់សង្កិនពួករាស្ត្រខ្មែរនៅតាមជាយព្រះរាជអាណាចក្រភាគខាងលិច ហើយលុកចូលមកដល់នគរកំពែងពេជ្រ ដែលមានមហាឧបរាជខ្មែរព្រះនាម

"ព្រះពមកជ" ឈរគ្រប់គ្រងនៅទីនោះ ដោយព្រះពមកជមិនដឹងខ្លួនជាមុន ៗ កាលលើកទ័ពទៅដល់ជាយក្រុងកំពេងពេជ្រ ព្រះព្រហ្មកជ ក៏ចូលទៅជួបនឹងព្រះពមកជ ទទួលក្រឡេកទៅឃើញព្រះកែវមរកតនៅក្នុងព្រះវិហារក្នុងក្រុងនោះក៏ទូលសុំយកទៅ ព្រះពមកជទើសទាល់ ក៏លើកឲ្យទៅទាំងមិនសុំគ្រ ៗ ព្រះព្រហ្មកជកាលបានព្រះកែវមរកតទៅហើយក៏គិតព្រួយបារម្ភក្រែងខ្មែរលើកទ័ពទៅដណ្ដើមយកមកវិញ ទើបគិតធ្វើឧបាយក្រឡៃព្រះកែវមរកតបំបាត់ដានកុំឲ្យខ្មែរឃើញ គឺយកបាយអមកបូកស្រោបព្រះកែវមរកត ឲ្យមើលឃើញហាក់ដូចជាព្រះពុទ្ធរូបធម្មតា ហើយយកទៅលាក់ទុកយ៉ាងគត់មត់ ៗ

រឿងសៀមតាំងឥស្សរភាពនៅក្នុងខែត្រខ័ណ្ឌនៃព្រះរាជអាណាចក្រនោះ មិនបានផុតទៅអំពីព្រះកាណ៌របស់ព្រះបាទសូរ្យវ័ន្តទេ កាលទ្រង់ជ្រាបហើយ ក៏ត្រាស់ឲ្យកងទ័ពលើកទៅក្រមាប់ពួកសៀមនោះ ឲ្យត្រឡប់នៅក្រោមម្លប់ព្រះបរមពោធិសម្ភារដូចដើមវិញ ៗ សៀមគោងនៅក្រោមអាណាខ្មែរតមកទៀត ដរាបដល់សតវត្សទី ១៨ ទើបអាចតាំងឥស្សរភាពបាន ដូចជានឹងមានពោលក្នុងវេលៈតទៅ ៗ

ឯព្រះកែវមរកតមិនបានត្រឡប់មកនគរវិញ នៅកប់បាត់ក្នុងស្រុកយោនកជៀងសែនតមក ៗ ការដែលមិនបានត្រឡប់មកវិញ ប្រហែលជាដោយហេតុព្រះបាទសូរ្យវ័ន្តទី ២ ទ្រង់និយមកាប់អានលទ្ធិវៃស្ណវ: ៗ

រឿងព្រះកែវមរកត ទើបមិនបានមកដំណាក់ក្នុងព្រះរាជហឫទ័យប៉ុន្មាន មុខ គួរឲ្យស្ដាយ ៗ

ក្នុងឆ្នាំ ព.ស. ១៦៦០ ក្រោយដែលទ្រង់សោយរាជ្យបាន ៤ ឆ្នាំ បានស្ដេចតែងរាជទូត ឲ្យនាំរាជសារទៅសូមចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិន ហើយនឹងប្រទេសចាម្ប៍ ដើម្បីជាប្រយោជន៍ក្នុងផ្លូវរដ្ឋប-សាសនោបាយ ៗ ប្រទេសទាំងពីរនេះ ក៏ព្រមទទួលសម្ពន្ធមេត្រីភាពផងដោយរីករាយ ហើយតែងរាជទូតឲ្យនាំរាជសារមកតបវិញតាមសមគួរ ៗ ប្រទេសកម្ពុជាបានចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិន រាប់ជាគ្រាទី ៧ ក្នុងរដ្ឋកាលនេះ ៗ

ចំណែកឯប្រទេសចាម្ប៍ សូម្បីមានព្រំប្រទល់ជាប់គ្នានឹងប្រទេសកម្ពុជាជាយ៉ាងវែង តែក៏មិនបានជាមិត្រជិតដិតគ្នាប៉ុន្មាន ច្រើនតែជាអរិនឹងគ្នាតាំងអំពីដើមមក ទើបតែនឹងមកប្រាកដក្នុងរដ្ឋកាលនេះថា បានចងមេត្រីភាពនឹងគ្នា តែនេះក៏ដោយកុសលោបាយរបស់ព្រះបាទសូរ្យវរ្ម័ន ដូចជានឹងមានប្រាកដទៅខាងក្រោយ ៗ

កាលចងសម្ពន្ធមេត្រីភាពហើយ ទ្រង់បានលើកទ័ពហ្លួង សឹងមានសេនាដំរីជាយ៉ាងច្រើន ទៅវាយប្រទេសកៅជី (យួន) ដែលបេះតែរុករានទន្ទ្រានយកជាយព្រះរាជអាណាខេត្តខ្មែរ រ៉ែកខាងលើជាញឹកញយ ៗ កាលកងទ័ពខ្មែរលើកទៅដល់ ទ័ពយួនក៏លើកចេញមកច្បាំងត

ទល់ តែទប់ឥទ្ធិពលកងទ័ពខ្មែរពុំបាន កងទ័ពខ្មែរបានវាយលុករហូតទៅដល់ស្រុកង៉ែអាន ទើបលើកទ័ពត្រឡប់មកព្រះនគរវិញ ។

កន្លងមក ៤ ឆ្នាំ(១) ទ្រង់លើកទ័ពទៅវាយកៅដីម្តងទៀត ដោយហេតុកៅដីមិនរាងចាល ។ សង្គ្រាមគ្រានេះទ្រង់វាយរហូតដល់ស្រុកតាន់ហ្វ ទ្រង់ប្រកាសឲ្យស្រុកដែលវាយបានទាំងប៉ុន្មាន ជាចំណុះប្រទេសកម្ពុជា ហើយស្តេចលើកទ័ពត្រឡប់មកព្រះនគរ ។

ក្នុងវេលានោះ ដែនដីដែលជាប្រទេសលាវ ដូចយ៉ាងហ្លួងព្រះបាងនឹងវៀងច័ន្ទន៍ជាដើម ក៏ជាអាណាខេត្តរបស់ខ្មែរដែរ ។

កាលស្រេចសង្គ្រាមកៅដីហើយ ព្រះបាទសូរ្យវ៉ុនទ្រង់លើកទ័ពហ្លួងទៅវាយប្រទេសចម្ប៉ា ជាការសងសឹកចាម្ប៉ា ដែលមានគំនិតខូចបានលើកទ័ពជើងទឹកមកលុកក្រុងស្រីយសោធរបុរៈ ក្នុងកាលចុងរជ្ជកាលព្រះបាទហសិវ៉ុនទី ៣ ដែលក្នុងពេលនោះប្រទេសកម្ពុជាបានទទួលគ្រោះថ្នាក់យ៉ាងធ្ងន់ ដោយត្រូវទឹកធំលិចយ៉ាងខ្លាំង ដូចមានពោលហើយ ។ កងទ័ពខ្មែរវាយលុកចូលដល់ក្រុងវិជ័យ ចាប់ព្រះរាជាចាម្ប៉ា ទ្រង់ព្រះនាមស្រីជយឥន្ទ្រវ៉ុនបាន ។ តែក្នុងទីខ្លះថា ព្រះរាជាអង្គនេះរត់ចោលព្រះ

---

១ ក្នុងប្រវត្តិសាស្ត្រសាកល (សៀម) ភាគ ៩ ថា ព្រះបាទសូរ្យវ៉ុនទី ២ លើកទ័ពទៅវាយកៅដី ក្នុងឆ្នាំ ព.ស. ១៦៣១, ដល់មកឆ្នាំ ព.ស. ១៦៣៤ ទៅវាយម្តងទៀត ។ ដល់ឆ្នាំ ព.ស. ១៦៨៨ ទៅវាយក្រុងវិជ័យ ។ គិតតាមសករាជនេះឃើញទ្រិលទៅមុខពេក ។

នគរបាត់ទៅ ។ ព្រះបាទសូរ្យវរ្ម័ន កាលទ្រង់មានជ័យជំនះដូច្នេះហើយ, ទើបត្រាស់ប្រកាសរួមប្រទេសចម្ប៉ា ចូលជាអាណាខែត្ររបស់កម្ពុជរដ្ឋ ទ្រង់តាំងព្រះរាជវង្ស ១ អង្គ ព្រះនាម "ហរិទេព" សិងត្រូវជាព្រះអនុជនៃព្រះអគ្គមហេសីរបស់ព្រះអង្គ ឲ្យនៅគ្រប់គ្រងរដ្ឋចម្ប៉ា ហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ ។ ប្រទេសកម្ពុជាក្នុងរជ្ជកាលនេះ មានព្រំប្រទល់ដ៏ធំទូលាយយ៉ាងអស្ចារ្យម្តងទៀត ។ វាសនារបស់ខ្មែរបានឡើងដល់កម្រិតខ្ពស់បំផុត ។

**ផ្នែកគ្រប់គ្រង**:- ព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់បាត់តាំងព្រះមហាឧបរាជឲ្យទៅគ្រប់គ្រងបច្ចន្តរដ្ឋ ដូចក្នុងរជ្ជកាលមុនៗ តែក្នុងរជ្ជកាលនេះ ព្រះមហាឧបរាជមានដល់ទៅ ៧ អង្គ គឺនៅស្រីធម្មនគរ ១ អង្គ, នៅកំពែងពេជ្របុរីកោសម្ពី ១ អង្គ, នៅលវបុរៈ បុរីស្រីអយុធ្យា ១ អង្គ, ហរិកុញ្ជ័យបុរីហៅហរិបុញ្ជ័យ ១ អង្គ, នៅនគរក្តិ ភាគខាងលើ ១ អង្គ, នៅឃ្លាំងក្នុងដែនកូស័ងស៊ីន ក្នុងបច្ចុប្បន្ននេះ ១ អង្គ, នៅវិជ័យ ក្នុងចម្ប៉ារដ្ឋ ១ អង្គ ។

**ផ្នែកកសាង**:- កាលស្រេចព្រះរាជសង្គ្រាមហើយ ព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់ឲ្យសាងប្រាសាទទេវស្ថាន ១ ដ៏ហើយដោយសិលា សិងមានទំហំធំមហិមា មានថ្នាក់ ៣ ថ្នាក់ នឹងមានលក្ខណៈល្អអស្ចារ្យ នឹងរកប្រាសាទឯណាក្នុងលោកនេះ ដែលមានទំហំនឹងលំអស្មើដូចគ្មាន ឲ្យឈ្មោះថា "វិស្ណុលោក" ។ (មាន៩ត)

## សាវតារវត្តកំពង់ចាប៉ជាភម

នៅឃុំពោធិ៍ ស្រុកកំពង់ឆ្នាំង ខែត្រកំពង់ឆ្នាំង

# ព្រះវិនយធរគណ ចៅអធិការវត្តនេះ រៀបរៀង

តនឹងចប់

( រង្កាន់លេខ ៣ )

---

លោកគ្រូចៅអធិការទី ៣ នេះ យកព្រះទ័យទុកដាក់ឲ្យវត្តអារាមចំរើនណាស់ដែរ តែកិច្ចការរបស់លោកមិនទាន់សម្រេច លោកក៏ទទួលអនិច្ចធម្មទៅ ។

ដល់មកឆ្នាំចបត្វាស័ក ព. ស. ២៤៦៥ គ. ស. ១៩២៣ ក្នុងរាជ្យព្រះករុណាស៊ីសុវត្ថិ លោកគ្រូព្រះនាម "អាម-លី" ព្រះជន្ម ២៤ ឆ្នាំ វស្សាគំរប់ ៤ ធ្វើជាចៅអធិការទី ៤ តមកទៀត, លោកគង់បាន ៧ វស្សា ក្នុងឆ្នាំឆ្លូវសប្តស័ក ១០ កើតខែផល្គុន ព. ស ២៤៦៨ គ. ស. ១៩២៦ បានកសាងព្រះវិហារថ្ម ១ ធ្វើពីស៊ីម៉ង់ត៍ ប្រកបគ្រឿងឈើ ដរាបហើយស្រេច ។ ដល់ឆ្នាំខ្លូវនពស័ក ព. ស. ២៤៨០ គ. ស. ១៩៣៨ បានកសាងសាលាធំ ១ ខ្នង ធ្វើពីស៊ីម៉ង់ត៍មកដល់ឆ្នាំវកទើបហើយស្រេច ។ ដល់មកឆ្នាំចអដ្ឋស័ក ព. ស. ២៤៨៩ គ. ស. ១៩៤៧ ចាប់កសាងសាលាសំរាប់ប្រជុំជន ១ ខ្នង ដល់ឆ្នាំជូតសំរិទ្ធិស័ក ព. ស. ២៤៩១ គ. ស. ១៩៤៩ ទើបហើយស្រេច ។

តាំងពីព្រះជន្មគំរប់ ២៧ ឆ្នាំទៀតមក ក្រៅពីកសាងរបស់ធំៗ លោកកសាងកុដិតូចៗ និងចេតិយនិងសាលាបង្រៀនជាដើម ដម្កល់ទុកក្នុងទីវត្ត ដរាបដល់បច្ចុប្បន្ននេះ ។

## ពិធីផ្តើមកសាងវត្តជាដំបូង

ដើមឡើយព្រឹទ្ធាចារ្យក្នុងស្រុកត្រូវស្វែងរកលោកអ្នកចេះដឹងទាំងឡាយ ទោះជាបព្វជិតក្តី គ្រហស្ថក្តី មកជួយពិចារណាមើលកន្លែង បើឃើញថាទីកន្លែងណាសមគួរហើយ ត្រូវធ្វើពាក្យសុំច្បាប់សុំអនុញ្ញាត អំពីព្រះករុណាជាម្ចាស់ជីវិតលើត្បូង លុះបានអនុញ្ញាតហើយទើបបោះគោលចារិកទទឹងបណ្តោយទីវត្ត តូចឬធំតាមភូមិភាគផែនទីដី ។ ដល់ពេលកសាងព្រះវិហារថ្មី មុនដំបូង មានរៀបពិធីបូលភូមិ (ឬពិធីមង្គលឫក្ស), ពួកជាងដែលជាអ្នកឈ្មាសវៃ ក្នុងកិច្ចកសាងព្រះវិហារ មកវាស់វែងបែងបត់ខ្នាតទទឹងបណ្តោយព្រះវិហារ បោះឫស្សគ្រប់ទិសទាំង ៨ ហើយរៀបធ្វើរានទេវតា ១ រានព្រះយមរាជ ១ ក្នុងទីខាងមុខវិហារ ហើយធ្វើស្វាធ័រដោតគ្រប់ទិស (ជួនឃើញធ្វើរានទេវតាគ្រប់ទិស) ។ រានទិសនេះមានដាក់វត្ថុតាមទំនៀមធ្លាប់ដាក់ មានស្វាធ័រ ១ គូ និងស្លាបារីជាដើម ។ រានធំខាងមុខមានដាក់បាយសុី ៥ ថ្នាក់ ១ គូ ។ និងមានទៀន ៥ ធូប ៥ ជាដើម, ហើយមានដាក់សំពត់អាវពណ៌ខៀវ-លឿង-ក្រហម និងវត្ថុមានគ្រឿងមាសប្រាក់ជាដើមផង, ទើបព្រឹទ្ធាចារ្យអ្នកចេះដឹងឲ្យជីករណ្តៅ ១

ចំកណ្ដាលព្រះវិហារថ្មី ជំរៅប្រមាណជា ៧ ឬ ៨ តឹក ហើយអុជអប់រណ្ដៅដោយទៀនធំធូប រួចយកពាង ១ តូចល្មមអប់ទឹកដាក់ពេញ លើកដាក់ទៅក្នុងរណ្ដៅនោះ ៗ ដល់ពេលម៉ោង៦-៧ល្ងាច រៀបពិធីសំដែងព្រះបរិត្ត, អាចារ្យអារាធនាសីល រួចសូត្រប្រកាសទេវតា ៗ ឯព្រះសង្ឃសំដែងព្រះបរិត្តតាមសមគួរដល់កាលវេលា ៗ

លុះព្រឹកព្រហាមឡើងជាថ្ងៃជ័យមង្គល ព្រះថេរានុត្ថេរព្រមទាំងពួកឧបាសកឧបាសិកាត្រូវទៅប្រជុំនៅទីព្រះវិហារថ្មី ឈរជុំវិញរណ្ដៅនោះ ទើបអាចារ្យសូត្របាឡីបួលភូមិថា :

អយំ ភូមិប្បទេសោ ៗ ល ៗ ជម្ពូទីបេ ឥកាសេ តិដ្ឋាហិ ៗ បីចប់ ៗ រួចអាចារ្យបួងសួងឧទ្ទិសដល់គុណព្រះរតនត្រ័យព្រមទាំងទេវតា សុំឲ្យទីវត្តថ្មីនេះប្រកបដោយសេចក្ដីសុខ-ចំរើនដរាបដល់ ៥០០០ ព្រះវស្សា, រួចយកដុំអិដ្ឋធំគ្របមាត់ពាងឲ្យជិត លុបដីពីលើ ស្រេចកិច្ចតែប៉ុណ្ណេះ ៗ

ន័យមួយទៀតគេមិនដាក់ពាងទឹកទេ, គឺយកថ្ម ១ ដុំល្មមលើកម្នាក់ រួច មកចងស្លាកឲ្យមានខ្សែកាន់, លុះដល់ពេលវេលាហើយ ព្រះថេរជាប្រធានាធិបតី ព្រមទាំងពួកព្រះបរិស័ទនិមន្តនាំអញ្ជើញទៅកាន់ទីសន្និបាត, ព្រះថេរជាប្រធានាធិបតីពោលព្រះបាឡីថា អយំ ភូមិប្បទេ-សោ វិសុំគាមោ ហោតុ ៗ បីចប់ ៗ រួចលោកលើកដុំថ្មដាក់ទៅ

ក្នុងរណ្ដៅនោះ ហើយមានថេរវាចាអធិប្បាយអំពីដីវត្តនឹងថ្មនេះតាមន័យផ្សេង ៗ រួចលោកបួងសួងដូចសេចក្ដីខាងលើនោះដែរ, ហើយលុបដីពេញរណ្ដៅនោះទៅវិញ ស្រេចកិច្ចតែប៉ុណ្ណេះ ។

## ពិធីបញ្ចុះសីមានឹងឆ្លងបុណ្យ

តាមទំនៀមទម្លាប់ស្រុកខ្មែរពីបុរាណរៀងមក កាលបើការកសាងព្រះវិហារថ្មីរួចហើយ គេតែងរៀបពិធីបញ្ចុះសីមានឹងឆ្លងបុណ្យ ។ តែបើវត្តណា ជាវត្តចាស់មានសីមាពីបុរាណៈដោយត្រឹមត្រូវល្អហើយ ទាំងសង្ឃមិនមានសេចក្ដីរង្កៀស វត្តនោះគេមិនបាច់បញ្ចុះសីមាថ្មីទៀតក៏បាន ។ កិច្ចរៀបពិធីបញ្ចុះសីមា ដើមឡើយត្រូវលោកជាប្រធានាធិបតី រកថ្មជានិមិត្តសីមា ឬសសីមា ៩ ដុំឲ្យល្អស្អាតកុំឲ្យបែះធា សំណុំ ២ ហត្ថ ១ ចំអាមពោះហោចទៅសំណុំតែ២ហត្ថក៏បាន, បើតូចជាងនេះពុំឡើងជាសីមា ។ ឯសន្ទឹកសីមាសម្រាប់ដាក់ខាងលើ ចង់យកឥដ្ឋ- ថ្មមករចនាដូចបុរាណធ្លាប់ធ្វើរៀងៗមកក៏បានឥតទាស់ ។ ឯទីជុំវិញព្រះវិហារនោះត្រូវបោសសំអាតឲ្យស្អាតល្អ ទើបលោកប្រធានាធិបតី (អាចារ្យ) យកខ្សែមកវាស់បោះប្លង់រណ្ដៅសីមា គឺវាស់អំពីសំយាបព្រះវិហារចេញទៅក្រៅ៤ហត្ថ, ហើយបោះប្លង់គ្រប់ទិសទាំង ៨ ។ បើទីព្រះវិហារធំ នឹងចង់បញ្ចុះឲ្យធំទៅទៀតក៏បាន តែកុំឲ្យលើសអំពី ៣ យោជន៍ ។ បើព្រះវិហារតូចឲ្យបញ្ចុះល្មមព្រះសង្ឃ ២១ អង្គគង់ហត្ថបាសបាន, បើតូចឬធំហួស

កំណត់នេះមិនឡើងជាសីមាឡើយ ។ លោកប្រធានាធិបតីត្រូវពិចារណាមើលក្រែងមានសីមាចាស់ពីមុនណា បើមានឲ្យបញ្ចុះសីមាថ្មីក្រៅសីមាចាស់ ទើបឡើងជាសីមាបាន ។

## ឯសីមាខុសមាន ១១ បំពូក គឺ

១ – ភូមិសីមាតូចពុំចុះភិក្ខុ ២១ អង្គ, ២ – សីមាធំកន្លងលើស ៣ យោជន៍, ៣ – សីមាមាននិមិត្តដាច់, ៤ – យកស្រមោលភ្នំ-ឈើជានិមិត្ត, ៥ – គ្មានយកវត្ថុអ្វីជានិមិត្ត, ៦ – ភិក្ខុហត្ថបាសឈរខាងក្រៅសីមាហើយសន្មតសីមា, ៧ – យកស្ទឹងសន្មតជាសីមា, ៨ – សន្មតសមុទ្ទជាសីមា, ៩ – សន្មតសីមាកន្លងជាតស្រះ (ស្រះកើតឯង), ១០ – យកសីមាលោកមុន មកធ្វើយជានិមិត្តសីមាឯក្រោយ, ១១ – យកសីមាឯក្រោយទៅបញ្ចុះគ្របលើសីមាមុន ឬចូលកន្លងសីមាមុន ។ សីមាខុសទាំង ១១ នេះពុំឡើងជាសីមាឡើយ ។

## ឯសីមាត្រូវនោះមាន ៣ គឺ

១ – យកថ្មឈើខ្ទឹមខ្លាប់បិតថេរយកមកធ្វើជានិមិត្តសីមា ។

២ – កាលបញ្ចុះសីមានោះឲ្យនិមន្តភិក្ខុមានសីលធម៌ល្អស្រគត់ស្រគំមកហត្ថបាស បើក្រែហោចណាស់ទៅឲ្យបាន ២ អង្គ បើច្រើនលើសនេះទៅជាមហាប្រសើរ ។

៣ – លោកជាវិនយធរ-ធម្ម-អ្នកសូត្របញ្ចុះសីមានោះ គេត្រូវរក លោកដែលស្ទាត់ក្នុងវិធីអក្ខរៈ មានគរុលហុជាដើម ។

លោកអាចារ្យត្រូវបង្គាប់ឲ្យទាយកជីករណ្ដៅសីមាឥន្ទខីលចំពោះមុខព្រះកក្រព្រះ ឲ្យវាស់អំពីសីមាទិសបូព៌ាទៅទិសបស្ចិម បត់ពាក់កណ្ដាលស្មើគ្នា ឲ្យវាស់អំពីសីមាទិសទក្សិណទៅទិសឧត្តរបត់ពាក់កណ្ដាលស្មើ, ហើយបោះឫស្សជីករណ្ដៅឥន្ទខីល ជំរៅ ៤ ហត្ថក៏បាន ២ ហត្ថក៏បាន, ហើយឲ្យវាស់អំពីសីមាគ្រប់ទិសចេញទៅ ៤ ហត្ថទៀត, ឲ្យផ្ចើកជវ័តិដោតឆត្រត្រួតជុំវិញព្រះវិហារ ហើយផ្ចើកទេវតាទាំង ៨ ទិស ព្រមទាំងជន្ទង់ គ្រប់ទិសទាំង ៨ ។ ដល់ពេលសំដែងព្រះបរិត្ត ឲ្យរៀបបណ្ណាការបូជាទេវតា បង្គំគោមពល់ជន្ទង់, រួចនិមន្តព្រះសង្ឃសំដែងព្រះបរិត្តអញ្ជើញអស់ទេវតា, ឯឫសសីមានឹងសន្ទឹកសីមានោះឲ្យយកទៅដាក់ក្នុងព្រះវិហារទាំងអស់ ។ លុះសូត្រមន្តជាគំរប់ថ្ងៃ ៣ ហើយ អាចារ្យអារាធនាសីល រួចឲ្យអស់ទាយកទាំងប៉ុន្មាននៅអ្នកដើមការវេរទីជាវិសុំគាមថា

ឧ មោ តស្ស ៣បប់ ម យំ ភន្តេ សីលវិសុទ្ធិ សង្ឃោ យោឧទាសការតដា ។ ល ។ សង្ឃស្ស ឧណោដេម ។ ទុតិយម្បិ ។ តតិយម្បិ ។

ព្រះសង្ឃទទួលសាធុ ។ រួចវេរបញ្ចុះនូវនិមិត្តថា សារីបុត្តមោគ្គល្លានោឧយោ ។ ល ។ តំ សត្ថុំ អម្ហាកំ វិហារស្ស ឧណោដេម ។ ទុតិយម្បិ ។ តតិយម្បិ ។

រួចនិមន្តព្រះសង្ឃសំដែងព្រះបរិត្ត ចប់ហើយអញ្ជើញអស់សីមាទៅដាក់គ្រប់ទិសទាំង ៨ ហើយឲ្យទុកខ្សែសិនបោះឬស្សីអមសងខាងមាត់រណ្ដៅសីមាជុំវិញ ។

លុះព្រឹកឡើង អស់ព្រះសង្ឃថ្វាយបង្គំព្រះបើកអរុណរួចហើយ, អស់ទាយកដើមការ បញ្ចុះសីមាឥន្ទខីល, ទិសបូព៌, អគ្នេយ៍, ទក្សិណ, និរតី, បស្ចឹម, ពាយ័ព្យ, ឧត្តរ, ឦសាន ។ លុះស្រេចកិច្ចបញ្ចុះហើយ ទាយកចេញមកក្រៅកដរ័ត ប្រយ័ត្នកុំឲ្យមានឆ្កែ ឆ្មា-មាន់-ទា ដាដើមចូលក្នុងកដរ័តឬហោរម្ភង ប្រយ័ត្នកុំឲ្យព្រះសង្ឃនិមន្តចេញចូលទៅទៀបខាងក្រៅកដរ័តនោះឡើយ, បើមានហេតុដូច្នេះ ឲ្យទាយកប្តឹងព្រះសង្ឃរើសូត្រញត្តិជាថ្មីទៀត ។ ឯព្រះភិក្ខុសង្ឃត្រូវសម្តែងអាបត្តិ ។ រួចហើយឲ្យសូត្រថា សព្វេ ពុទ្ធា ពលប្បត្តា ។ល។ ពុទ្ធានំ សព្វសោ ។ រួចសូត្រ អាកាសដ្ឋាច ភុម្មដ្ឋា ។ល។ សោត្ថឹ គច្ឆន្តុ ទេវតា ។ ហើយឲ្យភិក្ខុ ១ អង្គសូត្រថា អយំ ភូមិប្បទេសោ វិសុំគាមោយេវ ហោតុ (៣ ចប់) ។ រួចព្រះសង្ឃរៀបឈរហត្ថបាសជុំវិញសីមាឥន្ទខីលឲ្យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ, រួចសូត្រដកសីមាឥន្ទខីលថា: សុណាតុ មេ ភន្តេ សង្ឃោ ។ល។ ឯវមេតំ ធារយាមិ ។ រួចសូត្រដកសីមាទិសបូព៌-អគ្នេយ៍ ទក្សិណ-និរតី-បស្ចឹម-ពាយ័ព្យ-ឧត្តរ-ឦសាន រួចសូត្រដកសីមាទិសបូព៌ត្រួ

ម្តងទៀត ហើយចូលទៅក្នុងព្រះវិហារវិញ, ទើបលោកធានាធិបតី ចាត់លោកវិនយធរ-ធម្ម ២ អង្គ ឲ្យចេញទៅដណ្តឹងនិមិត្តសីមាទិសបូព៌ ជាដើមថា បុរត្ថិមាយ ទិសាយ កឹំ និមិត្តំ ។ អាចារ្យឆ្លើយថា បាសាណោ ភន្តេ ។ ទើបព្រះវិនយធរ-ធម្ម-សូត្របឹងព្រះ ឧបជ្ឈាយ៍ថា ឯសោ បាសាណោ និមិត្តំ រួចសូត្រដណ្តឹងទៅ ទិសអគ្នេយ៍-ទក្សិណ-និរតី-បស្ចិម-ពាយ័ព្យ-ឧត្តរ-ឦសាន រួច សូត្រដណ្តឹងទិសបូព៌ត្រួតម្តងទៀត ។ ឯបាឡីត្រូវផ្លាស់តាមឈ្មោះទិស ទាំង ៨ ដូចរបៀបខាងលើ ។

រួចក្រមជុំនុំសង្ឃនិមន្តរៀបហត្ថបាស ឈរជុំវិញសីមាគន្ធខិល, សូត្រញត្តិសីមាដោយព្រះបាឡីថា សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា និមិត្តា កិត្តិតា ។ល។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

ស្រេចហើយប្រគេនទេយ្យទាន ដែលខ្លួនប្រុងទុកបូជាព្រះសង្ឃ ។

ពេលល្ងាចសូត្រព្រះពុទ្ធមន្ត, ព្រឹកឡើងនិមន្តលោកសូត្រជារធ្ជង កុសល, ពេលថ្ងៃរសៀលនិមន្តលោកទេសនាអានិសង្សសីមា, ទេស្នាចប់ ហើយនិមន្តព្រះសង្ឃមកជួបជុំក្នុងព្រះវិហារ រួចវេរដោយព្រះបាឡីថា ឥមស្មឹ វិហារេ ឥមានិ ខណ្ឌសីមានិ ឧទោសថបវារ-ណាសង្ឃកម្មករណត្ថាយ កាតុំសង្ឃស្ស សង្ឃស្ស

ឱណោជេម អត្ថាយ ហិតាយ សុខាយ ទីឃរត្តំ ៗ ទុតិយម្បិ ៗ តតិយម្បិ ៗ ព្រះសង្ឃទទួល សាធុ ៗ

ពិធីបញ្ចុះសីមាចប់

## សេចក្ដីបញ្ជាក់អំពីតែងរឿងនេះ

១ – រឿងសារតារវត្ត យើងតែងតាមសេចក្ដីកត់ហេតុ ដែលចៅអធិការមុនៗ សរសេរទុកមក ព្រមទាំងបានហៅចាស់ៗ មកសួរបញ្ជាក់ថែមទៀត ដើម្បីផ្ទៀបគ្នានឹងសេចក្ដីយល់របស់យើងខ្លះៗ ដោយកន្ទួន ដូចអំពីរឿងប្នល់ខ្សាច់ជាដើម ៗ .

២ – រឿងផ្ដើមកសាងវត្តជាដំបូង (បុព្វពិធីបូលភូមិ) យើងតែងតាមបានឃើញគេធ្វើ ទាំងតែងតាមអាចារ្យវត្តជាន់ចាស់ម្នាក់ឈ្មោះ "អ៊ូ" ដែលបានអធិប្បាយប្រាប់សព្វគ្រប់ តែអាចារ្យនេះអនិច្ចកម្មជាយូរឆ្នាំហើយ ៗ

៣ – រឿងបញ្ចុះសីមា និងធ្វើបុណ្យ យើងតែងតាមក្បួនបញ្ចុះសីមាពីបុរាណ ៗ ត្រង់បាឡីដកសីមាចាស់ និងបាឡីសូត្រញត្តិសីមាថ្មី ព្រមទាំងបាឡីវេរ សុទ្ធតែមានពិស្ដាររបស់គេ តែដែលយើងតែងនោះបំព្រួញចុះកុំឲ្យច្រើនទំព័រ ព្រោះយល់ថាមានក្នុងព្រះត្រៃបិដកហើយ ៗ

ចប់សារតារវត្តបាចិនរាម

ប្រវត្តិរបស់អេសុប

# លោក ផេង - ជ្រឹវ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ភ្នំពេញ

ប្រែពីបារាំងមកជាខ្មែរ

(ត ចប់)

---

ពេលនោះ អេសុបមានប្រពន្ធហើយ តែគ្មានកូន, លោកបានសុំមាណពម្នាក់ឈ្មោះអេនុះ (Ennus) ធ្វើជាកូនចិញ្ចឹម, អ្នកនេះជាអ្នកមានពូជអម្បូរត្រកូលខ្ពង់ខ្ពស់ តែជាបុគ្គលអកតញ្ញូ, លុះអេសុបដឹងរឿងនេះក៏ដេញចេញពីផ្ទះ ៗ ដើម្បីសងសឹកអេនុះក៏ធ្វើសំបុត្រក្លែងមួយ ហើយយកទៅថ្វាយព្រះចៅលីសេរុះ ៗ សេចក្តីក្នុងសំបុត្រនោះថា: "អេសុបមានចិត្តអាក្រក់ទៅចូលដៃ ជាមួយនឹងស្តេចជាគូដៃដែលចង់ប្រឡងរាស្ត្រនឹងព្រះអង្គ" ៗ ព្រះរាជា លុះទ្រង់ជ្រាបតាមត្រានឹងសុំញៀឈ្មោះក៏ទ្រង់ខ្ញាល់ ហើយបង្គាប់សេនាបតីម្នាក់ឈ្មោះ ហេរ៉ីពុះ (Hernippus) ដែលជាសម្លាញ់របស់លោក ឲ្យយកលោកទៅសម្លាប់ចោល កុំជំរះរកខុសត្រូវឡើយ ៗ តែហេរ៉ីពុះស្រង់ជីវិតរបស់អេសុបគ្មានឲ្យនរណាដឹង ហើយយកលោកទៅចិញ្ចឹមទុកក្នុងទុងមួយ រហូតដល់ព្រះរាជាព្រះនាមណិក្តេណាបូ បានទ្រង់ជ្រាបថាលោកស្លាប់ហើយ ក៏នឹកស្មានក្នុងព្រះរាជហឫទ័យថា មុខជាយកព្រះបាទលីសេរុះឲ្យជាអ្នកថ្វាយសួយដល់ព្រះអង្គជាមិនខាន ៗ ម៉្លោះហើយព្រះអង្គហ៊ានលេងក្បាល់នឹងព្រះបាទ

លីសេរុះទៀត ហើយផ្ញើសារទៅឲ្យព្រះករុណាអង្គនេះ ឲ្យបញ្ជូននូវជាងទាំងឡាយដែលចេះសង់ប្រាសាទនៅលើអាកាស និងមនុស្សម្នាក់សម្រាប់ដោះប្រស្នាទៅឲ្យទ្រង់ ។ ព្រះបាទលីសេរុះកាលទ្រង់ទតសារសព្វគ្រប់ហើយ ក៏បញ្ជូនទៅឲ្យសេនាបតីនិងអ្នកប្រាជ្ញទាំងឡាយដែលពងវៃជាងគេក្នុងព្រះនគរពិចារណាមើល តែរកឈ្មោះណាមួយនឹងអាចដោះស្រាយនូវប្រស្នានោះពុំបាន ។ ព្រះរាជាដែលបានទ្រង់ជ្រាបថាគ្មានអ្នកណានឹងអាចដោះស្រាយបានដូច្នោះ ក៏ទ្រង់នឹកស្តាយអេសុបពេក ។ ទើបហេរ្មិព្វុះក្រាបបង្គំទូលថា អេសុបនៅរស់នៅឡើយទេ ។ ព្រះរាជាទ្រង់បង្គាប់ឲ្យគេហៅលោកមក ។ លុះលោកមកដល់ ព្រះរាជាអង្គនេះទ្រង់ធ្វើបដិសណ្ឋារកិច្ចយ៉ាងពេះពយ, ចំណែករឿងកំហុសលោកដឹងច្បាស់ថា អេនុះធ្វើសំបុត្រក្លែង តែលោកអត់ទោសឲ្យ ។ ចំណែកខាងប្រស្នារបស់ស្តេចនគរអេស៊ីប្ត (Egypte អេសុបឃើញហើយសើចញឹមៗប្រាប់ថា ចាំដល់វស្សានរដូវទើបបញ្ជូនជាងនិងវិសេសជនបុគ្គលទៅ ។ ព្រះបាទលីសេរុះទ្រង់ប្រទានទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់លោកត្រឡប់ឲ្យមកវិញអស់ រួចទ្រង់បើកអេនុះឲ្យទៅនៅជាមួយនឹងលោកទៀត តាមតែលោកចង់ធ្វើអ្វី ចូរប្រើឲ្យធ្វើតាមចិត្តចុះ ។ អេសុបក៏ព្រមទទួលយកអេនុះទុកជាកូនចិញ្ចឹមវិញ តែត្រូវដាក់ទណ្ឌកម្មបន្តិច គឺត្រូវស្តីប្រដៅដូច្នេះ: "ត្រូវកោតខ្លាចព្រះជាម្ចាស់និងព្រះមហាក្សត្រិយ៍របស់

ខ្លួន, ត្រូវធ្វើឲ្យខែងរែងនៅមុខសត្រូវ, ធ្វើឲ្យស្រួល បេះដូងសមដល់អ្នកដទៃ, ត្រូវថ្នមប្រពន្ធតែកុំប្រាប់ការណ៍សម្ងាត់, ត្រូវនិយាយតិច, ត្រូវបណ្ដេញចេញពីផ្ទះ នូវមនុស្សណាដែលនិយាយច្រើនឥតប្រយោជន៍នឹងមនុស្សមិនចេះយល់ទាស់, កុំបណ្ដោយឲ្យសេចក្ដីទុក្ខញាំញីបាន, ចូរប្រយ័ត្នទៅថ្ងៃស្អែកជានិច្ច ព្រោះថាសូវចាំយើងស្លាប់សិន សិមឲ្យបច្ចា-មិត្រនៃយើងមានកម្លាំងល្អជាជាងយើងធ្វើឲ្យរវល់ ឲ្យទទើសទទែងដល់មិត្ររបស់យើង ក្នុងវេលាដែលយើងរស់នៅ, ការណ៍ដែលត្រូវកុំឲ្យមាននោះ គឺកុំឲ្យមានអភិជ្ឈានូវព្រេងសំណាងនឹងសេចក្ដីសុចរិតនៃជនដទៃដៀតថាបើកាន់ឫកបែបនេះ ដូចជាធ្វើបាបតែខ្លួនឯង " ។ ការប្រៀនប្រដៅនឹងចិត្តល្អនៃអេសុប ហាក់ដូចជាដែកមួយយ៉ាងស្រួចចូលទៅចាក់ចំពូលបេះដូងរបស់អេន្នុះ ។ មិនយូរថ្ងៃប៉ុន្មាន គាត់នេះក៏ធ្វើនូវកាលកិរិយាទៅ ដោយការក្ដៅក្រហាយនឹងអកុសលកម្មនៃអាត្មា ។

អំពីរឿងក្នាល់នឹងព្រះចៅព្រះនាមណិក្តេណាបូ អេសុបចាប់យកសត្វឥន្ទ្រីយមកបង្រៀនឲ្យចេះពាំកញ្ជើ ហើយក្នុងកញ្ជើនោះមានដាក់កូនក្មេងម្នាក់ ។

លុះវស្សានរដូវមកដល់ លោកអញ្ជើញទៅប្រទេសអេស៊ីបជាមួយសត្វឥន្ទ្រីយនឹងក្មេងទាំងឡាយ ។ ចំណែកអ្នកស្រុកអេស៊ីបនៅចាំទទួលពាក្យចម្លើយនឹងអ្នកដោះប្រស្នាឥតគោគញញើតអ៊ីនោះ ក្នុងពេលដែល

លោកអញ្ជើញទៅដល់ ។ ព្រះបាទណាំក្តេណាបូដែលហ៊ានបញ្ជូនបញ្ហាទៅ ដោយទឹកក្នុងព្រះទ័យថា: អេសុបស្លាប់មែន, តែលុះលោកទៅដល់ ស្រាប់តែទ្រង់ភ្ញាក់ព្រះអង្គព្រើត ។ បើប្រសិនជាទ្រង់ជ្រាបថាលោកនៅរស់ ទ្រង់ប្រាកដជាមិនហ៊ានលេងភ្នាល់នឹងព្រះករុណា លីសេរុះឡើយ ។ ព្រះករុណា ណាំក្តេណាបូ មានព្រះរាជឱង្ការត្រាស់សួរទៅអេសុបថា តើឯងមាននាំជាងនឹងអ្នកដោះប្រស្នាមកឬទេ? ។ លោកក្រាបបង្គំទូលស្នងថា វិសជ្ជនបុគ្គលគឺខ្ញុំទូលព្រះបង្គំនេះឯង ឯជាងសង់ប្រាសាទ ទូលព្រះបង្គំនឹងនាំយកមកថ្វាយត្រង់កន្លែងណាដែលទ្រង់ត្រូវការសង់ប្រាសាទ ។ លុះបរបារួចស្រេចកាលណា លោកលែងសត្វឥន្ទ្រីយដែលពាំកញ្ជើ ក្នុងកញ្ជើនោះមានក្មេងម្នាក់ស្រែកទារពីលើអាកាសមកថា ឲ្យបាយអមក ឲ្យថ្មនឹងឈើមក ។ លោកក្រាបបង្គំទូលព្រះចៅណាំក្តេណាបូថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមឲ្យគេយកគ្រឿងឧបសម្ភារៈទាំងឡាយមក ដ្បិតជាងមកដល់ហើយ"។ ព្រះរាជាក៏ទ្រង់ព្រមទទួលសុខចិត្តចាញ់មួយ១ ។ ព្រះអង្គទ្រង់ចោទមួយ១ទៀតថា: "យើងមានមេសេះមួយអាចស្តាប់ឮនូវសំរែករបស់សេះឈ្មោលដែលនៅឯស្រុកបាប៊ីឡូនបាន តើឯងត្រូវឆ្លើយថាដូចម្តេច?" ។ លោកសុំអង្វរទុករឿងនេះនឹងឆ្លើយថ្វាយដល់ថ្ងៃស្អែក ហើយលោកត្រឡប់មកកាន់ផ្ទះសំណាក់វិញ ។ លោកឲ្យក្មេងម្នាក់ចាប់ឆ្មាមួយបណ្តើរវាយតាម

ផ្លូវ ៗ ពួកអ្នកប្រទេសអេស៊ីប្ដ៍ដែលជាអ្នកគោរពសំពះឆ្មា លុះឃើញក្មេងធ្វើការមិនគួរគប្បីដូច្នោះ ក៏កើតចលាចលហើយនាំគ្នាកន្ត្រាក់ឆ្មាយកពីដៃក្មេង រួចទៅក្រាបបង្គំទូលនូវរឿងនេះចំពោះព្រះចៅផែនដី ៗ ព្រះបាទណិក្ដេណាបូទ្រង់បង្គាប់ឲ្យគេហៅអេសុបមកមួយរំពេច ហើយត្រាស់សួរថា: “ឯងមិនដឹងសត្វឆ្មា គឺសត្វជាទីគោរពរបស់យើងទេឬ? ហេតុអ្វីក៏ឯងធ្វើនូវកំហុសដូច្នេះ? ៗ លោកឆ្លើយតបឡើងវិញថា: “សូមទ្រង់ព្រះមេត្តាប្រទានទោស! ដ្បិតឆ្មាហ្នឹងមានកំហុសចំពោះព្រះករុណាលើសេរុះ ព្រោះយប់មិញ វាទៅស៊ីមាន់មួយរបស់ព្រះអង្គ គឺជាមាន់ល្អអស្ចារ្យដែលទ្រង់ទុកសម្រាប់ឲ្យរងាវរាល់ព្រឹក” ៗ ព្រះចៅណិក្ដេណាបូ ទ្រង់មានព្រះបន្ទូលត្រាស់ថា: ឯងនិយាយកុហក សត្វឆ្មាណាក្នុងមួយយប់អាចដើរបានឆ្ងាយម្ល៉េះ? ៗ អេសុបឆ្លើយតបទៅវិញភ្លាមថា មិនដែលមាន មេសេះណាអាចស្ដាប់នូវសំរែករបស់សេះឈ្មោលបានឆ្ងាយម្ល៉េះ! ៗ

តមក, ព្រះចៅដដែលមានព្រះរាជឱង្ការបង្គាប់ឲ្យគេអញ្ជើញនូវអ្នកប្រាជ្ញទាំងឡាយមានបញ្ញាយ៉ាងឆើត ៗ ដែលចេះខាងចំណោទយ៉ាងពូកែពីក្រុងហេលីយូប៉ូលិះមក ហើយប្រជុំគ្នាស៊ីលៀងព្រមទាំងអេសុបផង ៗ ក្នុងឱកាសដ៏ឧឡារិកនោះ គេចោទលោកថាដូច្នេះថា “មានព្រះវិហារមួយប្រតិស្ឋានលើសសរមួយ ដែលមានក្រុងដប់ពីរព័ទ្ធជុំវិញ,

ក្រុងមួយៗ មានចន្លល់សាមសិបនៅជុំវិញ, ចន្លល់មួយៗ មានស្រីក្រមុំពីរនាក់ មួយស មួយខ្មៅ ដែលដើរលេងមួយមុខ មួយក្រោយជាប្រក្រតី" ។ អេសុបឆ្លើយថា: "ប្រស្នាបែបហ្នឹង តែក្មេងក្នុងស្រុករបស់យើងក៏ចេះរកដែរ: ព្រះវិហារគឺលោកទាំងមូល, សសរគឺឆ្នាំ, ក្រុងទាំង ១២ គឺខែទាំង ១២, ចន្លល់ ៣០ គឺថ្ងៃទាំង ៣០, ឯស្រីក្រមុំពីរនាក់ដែលដើរលេងមុខ-ក្រោយ គឺព្រះអាទិត្យនឹងព្រះច័ន្ទ ។

ព្រឹកឡើង, ព្រះបាទណិក្តេណាបូ ទ្រង់ប្រជុំអស់នាម៉ឺនមន្ត្រីតូចធំនឹងមិត្តភក្តិទាំងប៉ុន្មានហើយមានព្រះរាជឲ្ការថា: "ចូរអ្នកទាំងឡាយមើលចុះ មនុស្សមានរូបវិកលវិការ មុខមាត់ស្ទើរតែមិនមែនជាមនុស្សដូចគេផងទាំងពួង មិនគួរសោះឡើយ ព្រោះតែមនុស្សបែបហ្នឹងមកឲ្យព្រះចៅលីសេរុះមានជ័យលើយើង អញគិតសព្វៗទៅដូចជាតប៉ម៉ល់ក្នុងចិត្តអម្ពែះ អំពីរឿងជំនះនេះ" ។ ក្នុងខណៈនោះ មានមនុស្សម្នាក់ទោទអេសុបមួយប្រស្នាទៀតថា: "ចូរអ្នកឯងទោទសួរមកយើងម្តងមើល តែត្រូវអ្នកទោទចំពោះតែប្រស្នា ណា ដែលយើងមិនដែលដឹងមិនដែលឮ" ។

អេសុបចាប់សរសេរសំបុត្រមួយច្បាប់ ក្នុងសំបុត្រនោះពោលជាក់ថា: "ព្រះបាទណិក្តេណាបូទទួលសុខចិត្តជំពាក់ចំពោះព្រះចៅលីសេរុះនូវប្រាក់ចំនួនប្រាំរយហាសិបរៀល (៥៥០រ,០០)," រួចក៏យកដាក់ក្នុង

ស្រោមមួយបិទយ៉ាងស្អាត ហើយយកទៅប្រគល់ដាក់លើព្រះហស្ត របស់ព្រះបាទណាំក្តេណាបូមានទាំងបោះត្រាផង ។ មុននឹងបើកសំបុត្រ មើល, ពួកមិត្តភក្តិនៃព្រះរាជាអង្គនេះនិយាយមកគ្នាថា គេនឹងឃើញថា ធ្លាប់ដឹងធ្លាប់ឮទាំងអស់គ្នា ។ លុះបើកសំបុត្រឡើងកាលណា ព្រះ រាជាស្រែកឡើងថា នេះហើយបានបំពេញជាកំហុសយ៉ាងធំកងលោក, ខ្ញុំយកអ្នកពល់គ្នាធ្វើជាសាក្សី ។ ទើបអ្នកទាំងនោះទទួលព្រមគ្នាថា យើង ប្រាកដជាមិនដែលដឹងមិនដែលឮសោះឡើយ ។ អេសុបសួរថា: "ម៉េច ត្រូវចិត្តរបស់អស់លោកគ្រប់គ្នាឬទេ? ដែលលោកបង់ដឹងនូវប្រស្នាដែល មិនដែលដឹងមិនដែលឮ" ។ ព្រះបាទណាំក្តេណាបូ បញ្ជូនលោក ត្រឡប់ទៅនគរវិញ ព្រមទាំងសួយសារអាករសម្រាប់យកទៅថ្វាយ ចំពោះព្រះចៅលីសេរុះ នឹងរង្វាន់ទានរបស់លោកផង យកស្មើរតែ មិនរួច ៕

លុះអេសុបត្រឡប់មកដល់នគរវិញកាលណា ព្រះបាទលីសេរុះ ស្តេចទ្រង់បាត់ឲ្យរៀបទទួលជាអ៊ឹកអធឹក ហើយទ្រង់សំដែងព្រះហឫទ័យ រីករាយនឹងសេចក្តីល្អជាពន្លឹក ។ រួចទើបទ្រង់បាត់ឲ្យជាងធ្លាក់រូបអេសុប មួយដំកល់ទុកគ្រាន់ជាអនុស្សាវរីយ៍ទៅថ្ងៃក្រោយ ។ ការបង់ឃើញបង់ ដឹងនឹងបង់រៀន នាំឲ្យលោកលះបង់នឹងមិនត្រូវការនូវសេចក្តីសុខកង ទ្រព្យសម្បត្តិនឹងការរាប់អាន ។ លោកចេញពីព្រះបាទលីសេរុះ ដើម្បី

វិលទៅកាន់នគរក្រិកម្តងទៀត ។ ព្រះរាជាអង្គនេះទ្រង់ស្រណោះសោកស្តាយនូវលោកពន់ពេក ហើយទ្រង់ផ្តាំថា: ចូរឯងត្រឡប់មកបង្ហើយនូវថ្ងៃរបស់ឯងនៅជិតយើងជាកុំខាន ។

បណ្តាទីក្រុងទាំងឡាយ ដែលអេសុបបានអាស្រ័យនៅជាយូរជាងនេះគឺក្រុងដែល្ហ (Delphes) ។ អ្នកស្រុកដែល្ហចូលចិត្តស្តាប់សុភាសិតរបស់លោកដែរ តែគ្មាននរណាមួយគោរពកោតក្រែងដល់លោកសោះ ។ លោកតូចចិត្តនឹងគេមើលងាយពេក ទើបនិយាយប្រៀបថា អ្នកស្រុកដែល្ហ ដូចជាកំណាត់ឈើដែលអណ្តែតតាមទឹក, មុនដំបូង កាលនៅឆ្ងាយគេស្មានថាជាវត្ថុអ្វីមួយដ៏មានដំឡៃណាស់ដែរ តែលុះមកដល់ជិតក៏ត្រឡប់ជាវត្ថុរកខ្លឹមសារគ្មាន ។ សេចក្តីឧបមានេះ ធ្វើឲ្យលោកមានគ្រោះថ្នាក់យ៉ាងធំបំផុត ។ អ្នកស្រុកដែល្ហមានគំនុំយ៉ាងមាំ ហើយមានបំណងនឹងធ្វើការសងសឹក ព្រោះខ្លាចក្រែងអេសុបយករឿងខ្លួនទៅដើរនិយាយប្រាប់គេជិតឆ្ងាយ ម្ល៉ោះហើយក៏នាំគ្នាគិតសម្លាប់លោកចោល ។ ដើម្បីញុំាងថេយ្យកិច្ចនេះឲ្យសម្រេច ក៏យកផ្តិលប្រាក់មួយទៅលាក់បង្កប់ក្នុងសម្ពាយខោ-អាវរបស់លោក ដើម្បីនឹងក្លែងចោទប្រកាន់ថាលោកលួចទ្រព្យគរុភ័ណ្ឌ ទោសនេះឯងត្រូវសម្លាប់ខ្លួនចោល ។

លុះអេសុបដើរចេញពីក្រុងដែល្ហកាលណា ហើយសំដៅទៅកាន់ក្រុងហ្វូស៊ីត (Phocide) ពួកអ្នកស្រុករត់តាមនូវលោកឈ្លបនិយាយចោទ

ប្រកាន់ថាលោកលួចផ្តិលរបស់គេ លោកស្បថស្បែរថាគ្មានយកទេ ។ លុះគេឆែកឆេរក្នុងសំពាយ ក៏ឃើញផ្តិលនៅខាងក្នុងរុំនឹងខោអាវ ។ លោកនិយាយយ៉ាងដូចម្តេចក៏គេមិនស្តាប់ ។ ពួកអាកំណាចចាប់លោកដាក់ច្រវាក់ ហើយនាំទៅដាក់គុកងងឹត ទើបកាត់ទោសថាត្រូវសម្លាប់ដោយកាត់ក ។ ពេលនោះគ្មានអ្វីមកជួយលោកបានឡើយ សូម្បីអាវុធធម្មតារបស់លោកក៏ឥតបានការ តែលោកនិយាយកាលណា គេចេះតែបំអកឲ្យត្រឡប់មកលោកវិញ ។ ដូចជាលោកនិយាយថាៈ មានកង្កែបមួយ ទៅបបួលកណ្តុរមកលេងឯផ្ទះរបស់ខ្លួន ដើម្បីបញ្ឆោតយកកណ្តុរទៅក្នុងទឹកឲ្យបាន កង្កែបក៏តាំងចងជើងរបស់ខ្លួនភ្ជាប់នឹងជើងនៃកណ្តុរ ។ លុះដល់ក្នុងទឹក កង្កែបមុជទាញកណ្តុរឲ្យឈ្លក់ទឹកស្លាប់អណ្តាលនឹងយកធ្វើជាអាហារ ។ កណ្តុរឈ្លក់ទឹកចំប្រឹងទាញងើបឡើងវិញ ។ មួយស្របក់កង្កែបក៏ទាញត្រឡប់ចុះទៅវិញ ។ កំពុងតែទាញចុះទាញឡើង ខ្លែងមួយក្រឡេកឃើញកណ្តុរ ហើយឆាបយកទៅដោយទាំងកង្កែបទៅផង សត្វទាំងពីរបានទៅជាចំណីរបស់សត្វខ្លែង ។ ម្នាលអ្នកទាំង-ឡាយសេចក្តីកំណាចរបស់អស់អ្នក មិនលែងមនុស្សណាមួយមានបុទ្ធមកសងសឹកនូវខ្លួនទេ កាលណាអញស្លាប់ទៅ អ្នកឯងរាល់គ្នាមុខជានឹងស្លាប់ដូចអញវិញជាមិនខាន ” ។

វេលាដែលគេនាំលោកយកទៅធ្វើគត់ លោករត់រួចទៅជ្រកក្នុងកូនព្រះវិហារមួយ ។ មនុស្សទាំងអស់ទៅតាមចាប់លោកទាញចេញពីក្នុងព្រះ

វិហារមកវិញ ។ អេសុបនិយាយទៀតថា: "អ្នកឯងទាំងអស់គ្នាមិនមានសេចក្ដីកោតក្រែងដល់ទីនេះសោះ គឺទីនេះហើយជាព្រះចេតិយ ។ មានថ្ងៃណាមួយគង់អ្នកទាំងអស់គ្នានឹងរកសេចក្ដីសុខគ្មាន សូម្បីទៅជ្រកកងព្រះវិហារក៏ដោយ ។ អ្នកទាំងឡាយមុខជាដូចសត្វឥន្ទ្រីយដែលដេញចាបសត្វទន្សាយ សត្វនេះរត់ទៅជ្រកកន្ធួចកញ្ចែ អង្វរសុំទោសក៏សត្វឥន្ទ្រីយមិនស្ដាប់ ។ តាំងពីពេលនោះមក ពូជសត្វឥន្ទ្រីយហិនហោចអស់គ្មានសល់" ។ ពួកមនុស្សទាំងនោះមិនរវល់អើពើនឹងសំដីរបស់លោក ហើយនាំគ្នាចាប់លោកបោះទៅកងជ្រោះស្លាប់ទៅ ។

មិនយូរមកបានប៉ុន្មានថ្ងៃ ខាងក្រោយដែលអេសុបស្លាប់ មានកើតជម្ងឺប៉េស្ដយ៉ាងសម្បើម អ្នកស្រុកស្លាប់ហិនហោចជាច្រើន ។ អ្នកនគរនាំគ្នាទៅបញ្ជាន់អ្នកតាសួរមើល តើធ្វើដូចម្ដេច ដើម្បីនឹងរម្ងាប់នូវរោគនេះបាន? ។ អារក្សប្រាប់ថា បើចង់ឲ្យរោគនេះរម្ងាប់ លុះត្រាតែអ្នកទាំងអស់គ្នាធ្វើបុណ្យមួយ ដើម្បីលន់តួសុំទោសចំពោះព្រលឹងរបស់អេសុបដែលខ្លួនបានជាខុសទៅសម្លាប់នូវលោក ហើយអង្វរសុំឲ្យព្រលឹងនោះទទួលសុខចិត្តអត់ទោសឲ្យទើបបាន ។ ព្រោះដូច្នោះអ្នកនគរទាំងឡាយនាំគ្នាសង់ព្រះចេតិយមួយថ្វាយចំពោះដួងវិញ្ញាណរបស់អេសុប ។ ការសម្លាប់អ្នកប្រាជ្ញនេះ មិនក្ដៅក្រហាយតែត្រឹមទេពតាឡើយ សូម្បីពួកមនុស្សក៏ក្ដៅក្រហាយដែរ ។ នគរក្រិកបញ្ជូនកងក្រវែលមកស៊ើបសួរចាប់យកមនុស្សទាំងនោះទៅធ្វើទោសជាទម្ងន់គ្រប់ៗគ្នា ។ **ចប់**

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៦

**La Lumière de l'Asie**

*លោក ស៊ីរ - អេតវ៉ីនអារណូលដ៍ តែង*

## លោក ប៉ាយ ប៊ុក ក្រមការតៅពុទ្ធសាសនបណ្ឌិត្យ

*ប្រែរៀបរៀង*

(តមក)

បើយើងបង់ឃើញទីកន្លែង ដែលព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ សូមអ្នកអញ្ជើញទៅទិសពាយ័ព្យ នៃច្បារឧទ្យានមួយពាន់នៅតាមជ្រោះភ្នំទន្លេគង្គា ដែលនៅជើងភ្នំមានរុក្ខាដុះស្រោង, ស្រោងមានស្លឹកខៀវខ្ចីដែលជាប្រភពនៃស្ទឹងនិលញ្ជន (Niladjan) និងមោហានៈ (Mohâna); បើដើរតាមមាត់ស្ទឹងទាំងពីរដែលមានរុក្ខាមហួអាស៍ mahouas) មានស្លឹកធំៗ ហោលម្ប់ត្រសុំសាខាត្រជាក់និងគុម្ពោតនៃព្រឹក្សជាតិសង្ក្រារ (Sansar) និងបីរ (bir) ។

រួចទើបអ្នកទៅត្រង់កន្លែង ដែលស្ទឹងទាំងពីរ មានខ្សែទឹកហូរក្ដីចាំងចែងជួបគ្នានៅកំពង់ផល្គុ (Phalgou) ដែលហូរកាត់ផែនសិលាទៅដំបន់គយានិងគិរីក្រហមនៃបរបារ (Barabar) ។ នៅជិតស្ទឹងនោះ មានដីទំនេរមួយឥតមានរុក្ខាដុះសោះឡើយ គេឃើញមានដុះតែឈើមានបន្ទា

បន្តិចបន្តួចទីងផ្ទៃរាបដែលពីដើមគេហៅថា ឩរុវេល (Ourouvelaya), នៅខាងចុងបំផុត មានអជនបទេសដែលមានពយោបក់គ្រីគ្រាត់រុក្ខា-លតាវល្លិ ព្រមទាំងស្មឹកត្រសុំសាខាមានពណ៌ខៀវខ្ចី លាយខៀវផ្ទៃមេឃ ដែលដុះឡើងបាំងនភាល័យជិត ហើយនៅខាងក្រោមព្រៃនោះមាន ស្ទឹងមួយ ដែលទឹកហូរស្រួលហើយមានបុប្ផាបទុមពណ៌ខៀវផ្ទៃមេឃ ដុះពាសពេញ ព្រមទាំងមច្ឆាជាតិហែលប្រាត់ហើយទឹងអណ្តើក ៗ នៅជិតនោះមានភូមិមួយហៅថា សេនានី (ប្រហែលជាសេនានិគម) មានគេហដ្ឋានប្រក់ស្បូវក្បាំងនៅកណ្តាលតាលវ័ន ហើយមានប្រជាជនជាអ្នកសុភាពធ្វើបរកទទួលទានដោយកសិកម្ម ៗ

នៅទីនោះប្រកបដោយរមទិយដ្ឋាន ព្រះបរមពោធិសត្វបាន ពិចារណា នូវសេចក្តីទុក្ខរបស់មនុស្សជាតិក្នុងសកលលោក នូវវិសុទ្ធមគ្គ គឺផ្លូវបរិសុទ្ធនៃសត្វ នូវលទ្ធិដែលមានក្នុងសៀវភៅគម្ពីរទាំងប៉ុន្មាន នូវហេតុផលដែលសត្វផ្សេង ៗ រស់ទៅក្នុងព្រៃ នូវរឿងអាថ៌កំបាំងនៃសេចក្តីស្ងប់ស្ងាត់ដែលធម្មជាតិទាំងអស់បដិសន្ធិមក នូវការស្ងាត់កំបាំងនៃសមន្ធការ (tenèbre) ដែលសត្វលោកវិនាសទៅវិញ នូវជីវភាពដែលមានសភាពទាក់ទងគ្នាដូចជាឥន្ទធនូ ដែលចុះមករពងពពកពីរបែប ដែលមេឃចុះអ័ព្ទ បានភ្ជាប់នៅលើអជ្ឈាកាសហើយមានចំហាយគន្ធាហុយចេញ ស្រាប់តែពណ៌ខៀវសក្តីស្រស់នៃឥន្ទធនូនោះលាយ

បាត់សាបសូន្យនៅកណ្តាលនភាល័យ ។ ព្រះបរមពោធិសត្វបានគង់នៅក្នុងព្រៃជាច្រើនខែ ដើម្បីនឹងធ្វើសមាធិកម្មដ្ឋាន, ដូនកាលក្លួចសោយព្រះក្រយាហារក៏មាន, ទ្រង់ដូនកាលដល់ចាកចេញពីសមាធិ ពិចារណាតាំងពីបច្ចូសសម័យរហូតដល់អធ៌ទិវា, ព្រះអង្គទ្រង់បានទតយល់នូវអំបែងដែលស្អូមទាននោះទទេគ្មានម្ហូបអាហារ ហើយទ្រង់បានសោយផ្លែឈើដែលស្ងួតស្រោកមានពណ៌ក្រហមឆ្អៅបានបេះទំលាក់មកលើទ្រង់ ។ ព្រោះហេតុដូចនេះ កាយពលរបស់ទ្រង់ក៏អន់ទន់ខ្សោយ, ព្រះរូបដែលទំព្យាមយាមដោយក្លាហានរកធម៌ ទៅជាស្គាំងស្គម បាត់អាការៈ ៣២ ដែលជាលក្ខណៈរូបនៃព្រះពុទ្ធ, ហើយព្រះរូបទ្រង់មិនបានដូចជាព្រះអង្គម្ចាស់ កាលដែលនៅក្នុងតរុណវ័យទេ ត្រឡប់ទៅជាដូចស្លឹកសាលព្រឹក្សក្រៀមស្វិតស្រពោន ដែលជ្រុះទៅជិតព្រះបាទារបស់ទ្រង់, មិនមែនដូចជាពន្លកនៃរុក្ខជាតិមានពណ៌ខៀវខ្ចី ដុះក្នុងនិទាឃៈរដូវនោះឡើយ ។

មានមួយថ្ងៃ ព្រះអង្គម្ចាស់មានព្រះកាយពលអន់ទន់ខ្សោយរហូតដល់ដួលសន្ទប់បាត់ព្រះស្មារតីនៅលើប្រថពី គេស្មានថាសោយព្រះទិវង្គត ដូចជាមនុស្សដែលត្រូវគេពិឃាត, មិនមានខ្យល់អស្សាសៈបស្សាសៈ, ហើយព្រះលោហិតឈប់ហូរក្នុងព្រះកាយព្រះអង្គ ដោយគេយល់ឃើញព្រះរូបនោះមានសភាពស្វិតស្គាំងពន់ពេក ហើយ

ស្ងៀមឥតកម្រើក ។ តែមាននាយមេសបាលម្នាក់ទទួលមកដល់ទីនោះ ហើយបានឃើញព្រះសិទ្ធត្ថផ្ទំមានត្របកព្រះនេត្របិទជិត, បបូរព្រះឱស្ឋជ្រួញដោយមានទុក្ខជាទម្ងន់ ហើយក្នុងពេលនោះទទួលភានុរង្សីបញ្ចេញចំហាយក្តៅអធិកទៅលើព្រះសិរ, ក៏កាច់មែករុក្ខាប៉ូមីយេរ (pommier) ដែលមានសំបុរកុឡាបស្រស់ប្រមូលរចនាជាក្បាច់បាំងព្រះភក្ត្រ មានឆព្វណ្ណរង្សីប្រកបដោយអច្ឆរិយភាព ។ រួចនាយមេសបាលនោះបានយកទឹកដោះពពែ ដែលដាក់ក្នុងថង់ស្បែកពាក់ទៅក្នុងព្រះឱស្ឋព្រះពោធិសត្វ ដោយក្រែងខ្លួនជាវណ្ណៈទាប ទំប្រយ័ត្នមិនឲ្យប៉ះពាល់ដល់អរិយបុគ្គល ដែលប្រកបដោយអភិជនភាពនិងសន្តុលក្ខណៈគួរឲ្យជ្រះថ្លាពន់ពេក ។ តែមានគម្ពីរសំដែងថា មែកឈើ សាប៉ូនីយេរ (Jablonnier) ដែលយកទៅដោតជុំវិញព្រះភក្ត្រព្រះបរមពោធិសត្វ ទៅជាមានជីវិតរស់មួយរំពេច មានសន្ទឹកផ្កាជាច្រើន ព្រមទាំងមានផ្លែសំបុរភ្លឺហើយប្រមូលជាចង្កោមគួរឲ្យអស្ចារ្យពន់ពេក, សំណុំរុក្ខជាតិនោះទៅដូចជាតែនត៍ (tente) នៃសំពត់ព្រែ មានជរជាយពណ៌សដូចជាប្រាក់ និងវត្ថុមូលមានពណ៌ក្រហមឆ្អៅ ដែលគេសង់សម្រាប់ព្រះមហាក្សត្រិយ៍កាលស្តេចយាងទៅក្រសាលបរបាញ់សត្វដូច្នោះឯង ។ ហើយបុគ្គលនោះក៏ក្រាបវន្ទាព្រះបរមពោធិសត្វដោយស្មានក្នុងចិត្តថា ព្រះអង្គជាព្រះអាទិទេព (Dieu), តែបន្តិចទៀត ព្រះបរមពោធិសត្វក៏ភ្ញាក់ឡើង ទ្រង់

បានសូមចូស្បែកនៃនាយមេសបាលដែលមានទឹកដោះពពែមកសោយ ។ នាយមេសបាលក្រាបបង្គំទូលតបមកព្រះអង្គវិញថា "ឱព្រះអង្គ ! ខ្ញុំព្រះករុណាមិនអាចថ្វាយចូស្បែកនេះទៅព្រះអង្គទេ ព្រោះខ្ញុំព្រះករុណាមានវណ្ណៈជាពួកសុទ្រៈ, ហើយការប៉ះពាល់នេះនាំឲ្យមន្ទិលសៅហ្មងដល់ព្រះអង្គ" ។ ព្រះអង្គតបទៅកាន់នាយមេសបាលថា: "សេចក្តីមេត្តានឹងកិច្ចដែលត្រូវការ តែងមានហេតុផលទាក់ទងគ្នាចំពោះសត្វលោកទាំងអស់ ដែលគេទុកជាបងប្អូនមានសាច់លោហិតជាមួយគ្នា ។ វណ្ណៈមិនមានក្នុងលោហិត ដែលហូរមានពណ៌ដូចគ្នាក្នុងសរសៃទេ, វណ្ណៈមិនមានទេក្នុងទឹកនេត្រាដែលហូរចេញពីចក្ខុគ្រប់ៗសត្វ ជាវត្ថុមានឱជារសប្រៃ; ហើយមនុស្សយើងមិនមែនតាំងពីចាប់បដិសន្ធិមកយកទាំងសញ្ញា "ទិល្កៈ" លើថ្ងាសនិងខ្សែព្រិសិដ្ឋជាប់នឹងកមកជាមួយផងទេ ។ អ្នកណាសុចរិត អ្នកនោះគេទុកជាអ្នកទ្វិជៈ (អ្នកមានកំណើតពីរដង) ហើយអ្នកណាប្រព្រឹត្តបាបអកុសលណាមក អ្នកនោះគេទុកជាបុគ្គលហីនភាព ។ ព្រោះហេតុដូចនេះ ចូរអ្នកឲ្យទឹកដោះនេះមកខ្ញុំអាស្រ័យផង; បើកាលណាខ្ញុំរកធម៌ដែលខ្ញុំមានឆន្ទៈស្វែងរកនោះឃើញ, អ្នកឯងមុខជានឹងបានទទួលនូវសុខផលមិនខាន" ។ ឱវាទនៃព្រះបរមពោធិសត្វនេះនាំឲ្យនាយមេសបាលនោះ មានបីតិព្រឺព្រួចសព្វអង្គា ហើយក៏យកចូស្បែកនោះថ្វាយទៅព្រះអង្គ ។ (មានត)

# ឧបក្កិលេសដប់ប្រាំមួយ

ពាក្យកាព្យ

ឃុនសុវិត្តិវេទី ឃួរ-អ៊ុន នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ថ្ងៃទី ៣ នៃកញ្ញា ឆ្នាំ គ.ស.

មួយពាន់តបួនរយកួយហាសិប

ឃួរ-អ៊ុនខ្ញុំសូមសំដែងតែងកាត់ប្រែប

ពីគ្រឿងត្រិបគីកិលេសដប់ប្រាំមួយ ។

ដែលជាស្នឹមរុំស្រោបឱបដួងចិត្ត

ស្អុកស្អាញស្អិតជាប់ស្អិតឥតរលួយ

បើមានហេតុស្រុះក្រុតងើបរង្គួយ

រួចតួមួយចេញមុខរងអារម្មណ៍ ។

ឯតួចិត្តបើឥតធម៌ទម័ក

មកជួយស្ទាក់ទាញញាក់គ្រៀកបង្ខំ

តែងដោយតាមកិលេសប្រែះស្រោចស្រំ

ហើយស៊ូផ្ញុំទ្រាំក្នុងភ្នក់ភ្លើងទុក្ខ ។

តែបើយើងយល់ដើងនៃកិលេស

រួចមិនធ្វេសខំទប់សព្វកលយុគ

គង់បានស្រាលស្រាកស្រេនស្រាន់ភក្ត្រ
មិនសូវទុក្ខក្រៀមក្រំដាំទុក ។
បេះគួរប្រៀនប្រៀនឲ្យចាំជាក់ពិត
ហើយត្រូវគិតរកំផងតាំងចិន្តា
ថាយកឈ្នះកិលេសទាំងនេះណា
ឲ្យលុះត្រាអស្ចារ្យគ្រលត់ឃ្លាត ។
គតិនេះខ្ញុំនឹងរៈពបចំនួន
ជាបទពាក្យប្រាំបួនទុកជូនញាតិ
តែសំខាន់មាតិកាច្រើនលើសលាត
សូមពួកញាតិអានកញ្ចក់ហក់កុំខាន ។

១ - អភិជ្ឈា ការលោភធនជនដទៃ
ដោយរំពៃលែកផងចិត្តគិតបង់បាន
នឹកវិរក់ឈ្លក់ខ្វល់វរគរកេងប្រាណ
ថាម្តេចបានជាអំរសរបស់ខ្លួន ។

២ - ធម៌ទោស: ការថ្នាំងថ្នាក់ព្រោះអារម្មណ៍
ណាមិនសមនាំសន្តានបានមួម៉ួន
តែងនឹកខ្នាញ់ពេញក្នុងពោះឈ្លោះក្នុងខ្លួន
តែសំងួនអាការក្រៅនៅមិនចេញ ។

៣ — ធម៌កោធ: ការខឹងដាក់ចេញអាការ
កាយវាចាតាមហេតុការណ៍ដែលទោម្នេញ
ឲ្យឃើញស្ដែងដល់គេឯងស្រែងពាសពេញ
ខាងក្រោយវិញទើបរែងក្រែងរអា ។

៤ — ឧបនាហ៍ ការគុំគួនមួនក្នុងចិត្ត
ចងគំនិតគិតគួបកាន់វ័ន្ទក្រោធក្ដា
ដោយបំណងនឹងសងសឹកទៅវិញក៏
តែមិនថាការមិនធ្វើទៅលើគេ. ។

៥ — ធម៌មក្ខ: ការលុបលាក់គុណប្រពៃ
ជនដទៃដោយបំភ្លៃតែរាសរេ
ពោលបង្អាប់ចាប់ថ្នាក់ថ្នល់ផ្ដល់ឲ្យគេ
ពុំនោះទេគេមេខ្លួនថាកូនវិញ ។

៦ — បលាស: ការតែកាសរ៉ាសវៃបុក
ដោយធ្វើឫកមុខមាត់ខ្លួនស្លួនបញ្ចេញ
ឲ្យត្រឹមស្មើឬលើសលើលោកជុំវិញ
ឲ្យគេជ្រិញឃើញមិនពេញតាមការណ៍ពិត ។

៧ — ធម៌ឥស្សា ការប្រណែនគេណ្ណ ឈ្នានីស
ព្រោះត្រិះរិះឃើញគេមានគុណពិសិដ្ឋ

ប្រកាន់ចិត្តមិនស្ងៀតកោតដោតស្នេហ៍ស្និទ្ធ
ប៉ងក្នុងចិត្តឲ្យតែគេប្រែអន្ធការ ។

៨ — មច្ឆរិយ៍ គឺកំណាញ់កាញ់ទ្រព្យទុក
ដោយលាក់មុខពុំចែកចាយកាយតាមការណ៍
ស៊ូធ្វើខ្សត់ហោចទុរគតយ៉ាងអស្ចារ្យ
ធ្វើអាការឲ្យគេថាអ្នកក្រណាស់ ។

៩ — ធម៌មាយា ការពុំជាពុតលាមក
បាបគម្រក់ដូចគម្រង់ក្នុងអន្ធក្រាស់
ស៊ូលាក់ខិតស្ងៀតបញ្ចេញដោយមានខ្មាស
ពុំប្រកាសឲ្យច្បាស់ក្រែងសាយទៅ ។

១០ — សាឋេយ្យៈ រឺអំនួតអួតថាគ្រាន់
គ្មានអ៊ីអន់មានតែជាន់ខ្ពស់ពេកគួរ
ទោះសំដីថ្លៃគំនិតគិតពក់ជ្រៅ
ទ្រព្យពង្សផៅសឹងសន្ធៅគ្មានគេដល់ ។

១១ — ធម៌ថម្ភៈ ការរឹងត្អឹងទ្រឹងវាហី
គ្មានសេចក្តីលៃធ្វើព្រួយខ្វាយខ្វល់
ដោយវាចាដែលគេហាថាមកដល់
កោងសែនសល់រឹងទឹងថ្កល់ដូចបង្គោល ។

១២ – សារម្ភៈ ការប្រែដងវែងសេចក្ដី

គេពោលខ្លីឯងបំភ្លៃត្នៃពាំនោល
គេថាត្រូវត្រូវតាមផ្លូវគួរសួពោល
ឯងខំទ្រោលចោលសំអុយទៅទាំងប្រឹង ។

១៣ – ធម៌មាន: ការកាន់ខ្លួនស្លូនគ្រងទុក

គេមើលមុខប្អុពុំមើលឯងព្រើលខឹង
ដោយកាន់ថាយ៉ាងអាត្មាធុនម៉ឹងៗ
ហ៊ានសំឡឹងពុំធ្វើដឹងពុំពប់អាន ។

១៤ – អតិមាន: មាក់ងាយគេថាគេអន់

ថោកពេកពន់យកជាគ្នាក់អាប់ប្រាណ
មិនពប់មុខទាំងធ្វើទុក្ខឲ្យរំខាន
ឲ្យគេបានក្ដីលំបាកយ៉ាកចិន្ដា ។

១៥ – ធម៌មទ: ការវង្វេងស្រវឹងវ័យ

ជាប់អាល័យអំពើពាលលាមកា
វ័យធ្មេញបាក់ថ្នាក់គេហៅពូបុត្តា
ហ៊ានផឹកស្រាឆ្កាដៃអួតល្បែងពុំល្អ ។

១៦ – បមាទ: ការធ្វេសលង់ផុងស្មារតី

បំភ្លេចក្ដីរក្សាខ្លួនស្លូនធម៌ស

បណ្តោយឲ្យអកុសលខ្វល់ដល់ក
អាសន្នក្រជិតទីធមរណ៍ទើបវិលត្រឡក ។
ឧបក្កិលេសដែលពោលនេះជាមន្ទិល
នាំចិត្តវិលផ្តិលក្តីសុខទុក្ខអនេក
ឲ្យក្មិចក្មកកករល្អក់ឈ្មោះប្រែកេក
ជាហេតុបែកសាមគ្គីពីសង្គម ។
ទាំងនាំឲ្យអន់ទន់ខ្សោយផ្តាយគំនិត
មិនមានគិតពិនិត្យធ្វើការឧត្តម
ដែលជាទ្រព្យជាប់ទៅមុខទុកឧបត្ថម្ភ
ឲ្យសន្សំទំតែសាងខាងសៅហ្មង ។
សូមលោកអ្នកមើលឲ្យជាក់កិលេសនេះ
រួចសូមរំះត្រិះកងចិត្តសង្កេតផង
គង់ឃើញថាកិលេសណាដូចណាហោង
សឹងនាំហ្មងនាំឲ្យម៉ៅក្តៅសន្តាន ។
យើងពុទ្ធជននៅធ្ងន់ដោយកិលេស
បើចេះមិនខំបេះប្រលេះប្រាន
នឹងបង់គ្រឿងដែលកើតទាន់ជុំទាន
ដំបូន្មាននៃព្រះពុទ្ធបញ្ញាការ ។
អើបងប្អូនខេមរៈកម្ពុជរដ្ឋ

ជាប់ពូជពង្សនគរវត្តរដ្ឋអស្ចារ្យ
សូមអ្នកផងតម្រង់ខ្លួនក្នុងធម៌អាថ៌
ជាបុញ្ញាភិសង្ខារជាតិទៅមុខ ។
តែកុំភ្លេចកសាងផ្លូវឲ្យកូនចៅ
ដែលគ្នានៅខាងក្រោយឲ្យបានសុខ
ដោយសារថ្វីការពិសីដែលធ្វើទុក
ឲ្យថ្កើងមុខកុំបីជាអាយ៉តគេ ។
ជនខាងក្រោយសុខទុក្ខដោយសារជនមុន
ជនខាងក្រោយនឹកព្រះគុណពុំភ្លេចទេ
បើជនមុនទុកកេរ្តិ៍គុណប៉ុនសាគរ,
តែបើគ្មានគុណកោះកេរ្តិ៍គេសូន្យឈឹង ។
ខ្មែរទាំងជាតិបើមារយាទខ្លាចតែស្លាប់
ខ្មែរនឹងអាប់ស័ក្តិនឹងហិនគ្មានគេដឹង
តែបើខ្មែរប្រថុយស្លាប់រួចចាប់ប្រឹង
តស៊ូនឹងឧបសគ្គដោយវិទ្យា ។
ខ្មែរគង់រស់មានកំពស់ដូចជាតិគេ
ព្រោះខ្មែរមេប្ដុមានជនមានប្រាជ្ញា
នាំខ្មែរតូបកសាងពូជឲ្យថាវរ
ក្នុងឥឡូវឥឡូវណា, សូមលាអើយ ! ។

# ពិធីទទួលសម្ដេចសង្ឃនាយក៏

នៅវត្តដំណាក់ សៀមរាប

## ព្រះមហា កែ - អឿន រៀបរៀង

ដោយបានទទួលបើរបញ្ជាការ នៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណ

---

កាលពីថ្ងៃចន្ទ ៤ កើតខែអស្សុជ ឆ្នាំខាល ទោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ៣០ តុលា គ. ស. ១៩៥០ នេះ នៅវត្តដំណាក់ខេត្តសៀមរាប មានពិធីរៀបទទួលបដិសណ្ឋារៈសម្ដេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ នឹងព្រះតេជព្រះគុណព្រះញាណពិវង្ស ហួត - តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដែលនិមន្តទៅសំដែងព្រះសទ្ធម្មទេសនា ក្នុងឱកាសបុណ្យកឋិននៃឧបាសកសួស - ឆេង ឧបាសិកាវ៉ាង - គីម ដែលដង្ហែពីភ្នំពេញ ទៅវេរប្រគេនព្រះសង្ឃក្នុងវត្តដំណាក់ សៀមរាប ដូចមានពិធីបុណ្យខាងក្រោមនេះ :

## ស៊ុំនៅខាងមុខវត្ត

មានស៊ុំខ្លោងទ្វារនៅចំកណ្ដាលផ្លូវមុខវត្តពីរ គឺខាងជើង ១ ខាងត្បូង ១, ស៊ុំនេះគេតាក់តែងរចនាដោយរបៀបរៀបរយល្អវិចិត្រដូចគ្នាទាំងពីរកន្លែង, សសរស៊ុំសុទ្ធតែស្រោបដោយស្លឹកដែ ក្រឹមនឹងរចនាដោយបានជួន ដរាបដល់កំពូល, មានផ្ទាំងតួអក្សរតូចធំដែលកាត់ក្រដាសពណ៌ខៀវ - ក្រហមបិទសន្ទឹងនៅមុខស៊ុំទ្វារ ៗ ស៊ុំទ្វារខាងជើងចារិកអក្សរថា "សួស្ដី សម្ដេចព្រះសង្ឃនាយក!", ស៊ុំទ្វារខាងត្បូងចារិកអក្សរថា

"បុណ្យកឋិនឧបាសក សួស - ឆេង ឧបាសិកាព៉ាង - គីម" ។ កំពូលសុំទាំងពីរនោះមានដោតទង់ជាតិតូចធំព្រោងព្រាត, ខ្លោងទ្វារដែលចូលទៅក្នុងវត្តមានសុំ ១ ទៀតដោតទង់ជាតិតូចធំ ជាច្រើនដូចៗគ្នាដែរ ។

## ពាងនៅមុខឧបដ្ឋានសាលា

នៅខាងមុខឧបដ្ឋានសាលា មានធ្វើពេងធំពីរខ្នង, ត្រង់កណ្តាលគេធ្វើពេងតូចកាត់ទទឹងពេងធំទាំងពីរ ។ ក្នុងពេងទាំងនោះមានរៀបចំដោយកម្រងផ្កាឈើ - ស្លឹកដៃក្រឹមខ្ចាត់ខ្ចែង ជាគ្រឿងលំអដ៏ត្រកាល ។ នៅខាងយ៉មុខឧបដ្ឋានសាលា មានធ្វើបុស្បុក ១ កំពស់ប្រមាណ ៩ ម៉ែត្រ, ខាងលើបុស្បុកនោះ ដាក់ដម្កល់ត្រៃធម្មាសនៈ សម្រាប់សម្តេចព្រះសង្ឃនាយកសំដែងព្រះសទ្ធម្មទេសនា ប្រដាប់ចនាដ៏វិចិត្រផ្សេងៗ មានអំពូលភ្លើងអគ្គិសនីធំ - តូច - វែង - ខ្លី បញ្ចេញពណ៌ស្វា ខៀវ - ស-ក្រហម ចិញ្ចែងចិញ្ចាចក្នុងវេលាយប់ ។ នៅមុខពេងមានមន្ទីរ ១ តូច បិទរូបថតដែលសម្តេចបានមកពីប្រទេសឥណ្ឌា ឲ្យជនានុជនមើល, គួរឲ្យអ្នកផងជ្រះថ្លាជាប់ចិត្តចង់មើលហើយមើលទៀត ក្រឡេកមើលពីចម្ងាយទៅគួរឲ្យមានចិត្តជ្រះថ្លា ទឹងខានទៅកាន់កន្លែងបុណ្យនោះមិនកើត ។ តាំងពីខ្លោងទ្វារកំពែងមុខព្រះវិហារទៅ មានធ្វើជារាជវត្តិព័ទ្ធសងខាងមគ្គាខ្ចាត់ខ្ចែង តែងរចនាវិចិត្រដោយធាងដូង, ស្លឹកដៃក្រឹម, ទង់ជាតិតូច - ធំនឹងទង់លេកវែងៗ អមសងខាងរាជវត្តិដរាបដល់ព្រះវិហារ គួរជាទីទស្សនាការដល់ជនានុជនដែលគមនាការទៅមកក្នុងពេលនោះ ។

## ថ្ងៃទី ១ គឺថ្ងៃចន្ទ ៤ រោចខែអស្សុជ

ម៉ោង ៤ រសៀលពួកពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថមានចំនួនច្រើនមកប្រជុំនៅវត្តដំណាក់ ។ ផ្នែកបព្វជិតទាំងក្នុងវត្តនេះទាំងនិមន្តពីវត្តនានាក្នុងខេត្តជាង ៣០០ រូប មានព្រះសុមង្គលសិលាចារ្យមេគណនិងព្រះគ្រូបញ្ញាវិជ្ជាអនុគណជាប្រធាន; ផ្នែកគ្រហស្ថមានចំនួនជាង ១.០០០ នាក់ ត្រៀមចាំទទួលសម្តេច ឈរដំរៀបគ្នាជាពីរជួរតាំងពីមុខវត្តដំណាក់ដរាបដល់មុខផ្សារសៀមរាប ។ តទៅវិថីខាងជើងផ្សារដល់ស្ពានថ្មមានពុទ្ធបរិសទ្យឈរដំរៀបគ្នា ១ ក្រុម ៗ ក្បែរចិញ្ចើមថ្នល់សងខាង ។ តាំងពីចុងស្ពានថ្មខាងកើតមកដល់ត្រឹស្ថានព្រះរាជប្រតិភូ មានពួកកុមារកុមារី សិស្សសាលារាជការ ឈរជាពីរជួរតាមចិញ្ចើមថ្នល់ មានហត្ថកាន់ទង់ជាតិគ្រប់ៗ គ្នា ដោយក្រុមៗ, ក្នុងក្រុមនីមួយៗ មានគ្រូម្នាក់ៗជាមេបញ្ជាការ, ពួកសិស្សទាំងនេះលោកអធិការ ម៉ែន - ឈុំ បានចាត់ការរៀបចំរង់ចាំទទួល ។ មានរថយន្តតូចៗ ៣ បរទៅរង់ចាំទទួលសម្តេចនៅខាងកើតស្ពានថ្មចំនួនជាង ១ គីឡូម៉ែត្រ, រថយន្តទាំងនោះគេឃើញលោករាជការខ្លះៗ មានព្រះរាជប្រតិភូជាដើមដែរ, មានរថយន្ត ៣ ទៀតឃើញលោកគ្រូមេគណ អនុគណ លោកគ្រូចៅអធិការខ្លះៗ និងលោកមហា ៤-៥ អង្គគង់, មានរថយន្ត ១ ទៀតដាក់ក្មេងពិណពាទ្យនិងបាសកខ្លះដែរ ។ ម៉ោង ៥ កន្លះ រថយន្តសម្តេចមកដល់ ប៉ុន្តែមិនទាន់

បានហែក្នុងពេលនោះក្តាមទេ, សម្តេចឲ្យរង់ចាំរថយន្តអ្នកចិនមកនឹងដង្ហែជាមួយគ្នា ។ លុះរង់ចាំកន្លះម៉ោង ឃើញរថយន្តមកដល់ខ្លះៗ តែមិនទាន់ជួបជុំគ្នា, ពេលនោះគេឲ្យរថយន្តសម្តេចនៅពីខាងមុខបង្អស់ ឯរថយន្តតូច-ធំ រៀបជាលំដាប់ៗ តាមក្រោយ បរទៅដល់ចុងស្ពានថ្មខាងកើត, កុមារកុមារីគ្រវីទង់ជាតិព្រាតៗ ឡើង ស្រែកហ៊ោកញ្ជ្រៀវជាកិត្តិយសទទួលសម្តេច ។ តាំងពីត្រឹមនេះទៅ រថយន្តក៏បរបន្តិចៗ, ពួកសិស្សសាលានឹងពុទ្ធបរិសទ្យដើរអមសងខាង, រថយន្តដង្ហែសម្តេចទៅរហូតដល់ផ្សារសៀមរាប រួចហែព័ទ្ធផ្សារ ១ ជុំ ឆ្លងស្ពានមុខផ្សារបត់ចូលទៅក្នុងវត្ត ។

ម៉ោង ៧ ហែទៅដល់វត្តដំណាក់, លោកទានាធិបតីនិមន្តសម្តេចឡើងគង់លើបុស្បក សម្តេចថ្លែងការទទួលអំណារនឹងជូនពរដល់ពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថ ដែលបានមកទទួលបដិសណ្ឋារៈដល់សម្តេច ។ ទីបំផុតសេចក្តីទទួលអំណារ សម្តេចមានព្រះពុទ្ធដីកាថា “បដិសណ្ឋារៈនេះមិនមែនពុទ្ធបរិសទ្យធ្វើឡើងដោយសេចក្តីគោរពចំពោះរូបខ្ញុំទេ, តាមដែលពិតនោះ កិច្ចនេះអ្នកកាន់ព្រះពុទ្ធសាសនាធ្វើឡើងដោយការប្រតិបត្តិតាមគារវធម៌ ទាំងជាកិត្តិយសដល់ប្រទេស” ។

រួចពីនេះសម្តេចទ្រង់សំដែងអំពីបដិសណ្ឋារៈ ២ យ៉ាងគឺ: អាមិ-សប្បដិសណ្ឋារ = ការរាក់ទាក់ទទួលគ្នាដោយអាមិស គឺខាទនីយភោជ-

ទីយាហារផ្សេងៗ មានបង្អែមនំចំអាបជាដើម ១; ធម្មប្បដិសណ្ឋារៈ=ការរាក់ទាក់ទទួលគ្នាដោយធម៌ គឺសំដែងធម៌ជាសត្បៀនគ្នាឬឲ្យទាន់ទូលគ្នា, រហូតដល់ ការសំដែងអាការគោរពរាប់អានឲ្យសមឋានៈនៃបុគ្គលជាឥស្សរៈ មានការក្រោកឡើងទទួលនឹងនិមន្តអញ្ជើញឲ្យឡើងកាន់អាសនៈដ៏សមគួរជាដើម ។ ការធ្វើបដិសណ្ឋារៈនេះរាប់បញ្ចូលក្នុងគារវតា ទាំង ៦. ហៅថា "បដិសណ្ឋារគារវតា" ។

សម្តេចថ្ងៃអំណរនេះចំនួនកន្លះម៉ោង លុះចប់ហើយ គេនិមន្តសម្តេចឲ្យទៅសម្រាក ក្នុងកន្លែងដែលរៀបចំទុកបំរុងប្រគេន ។

តាំងពីម៉ោង ៧ កន្លះទៅ គេអង្គាសភោជនាហារដល់ពុទ្ធបរិស័ទ្យដែលហែកឋិនមកពីក្រុងភ្នំពេញ ។

ម៉ោង ៩ កន្លះ លោកវរសេនីយត្រី (ឈួនម្ជុលពេជ្រ) នាំកងឯកទេសខ្មែរចំនួន ៥ រថយន្ត មកកាន់ធម្មស្សវនដ្ឋាន រួចលេងនូវភ្លេងជាតិនឹងរាំវង់ជូនបងប្អូនរួមជាតិស្តាប់មើល ។

ម៉ោង ១០ កន្លះ និមន្តព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត សំដែងធម៌ទេសនាដោយខ្មែរឡេសនសព្ទ ។ លុះចប់ធម៌ទេសនាហើយ កងឯកទេសចាប់ផ្តើមលេងភ្លេងរាំវង់តទៅទៀត រហូតដល់ម៉ោង ១ យប់ ទើបចប់ ។

(មានត)

## បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

### របស់ក្រសួងធម្មការ

### (តមក)

សញ្ញាប័ត្រលេខ ៧១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ-ញឹម នាមឆាយា វឌ្ឍីរប្បញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាចៅអធិការវត្តអង្គរំដួល ឃុំខ្សែត ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-វ៉ន នាមឆាយា ធម្មជោតោ កើតឆ្នាំវក អាយុ ២៩ វស្សា ១ ជាចៅអធិការវត្តខ្សែត ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពៅ-ញឹម នាមឆាយា សុវណ្ណសរេ កើតឆ្នាំខាល អាយុ ២៤ វស្សា ៤ ជាចៅអធិការវត្តត្រពាំងជា ឃុំពជមន្ទីរ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រ៉ុក-ឃុន នាមឆាយា ព្រហ្មត្ថេរសរេ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៧ ជាចៅអធិការវត្តអង្គស្វាយ ឃុំស្វាយរំពា ស្រុករំដួល ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួរ-ពុត នាមឆាយា ព្រហ្មសត្ថា កើតឆ្នាំជូត អាយុ ៦២ វស្សា ៤១ ជាចៅអធិការវត្តរវៀង ឃុំបាក់ក្តោង ស្រុករវៀង ខេត្តកំពង់ធំ ។-

សញ្ញាប័ត្រលេខ ៧២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង គិម នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំរោង អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុកខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ិន-ហ៊ី នាមឆាយា បញ្ញាថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៨ ជាចៅអធិការ វត្តអម្ពវនារាម ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៧២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ-ជឿក នាមឆាយា កសុត្តរោ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តសិរីសុន្ទរវង្សារាម ឃុំក្រចេះ ស្រុកក្រចេះ ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-សុខ នាមឆាយា សុវណ្ណត្ថេរប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ១២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៣៤ ចុះថ្ងៃពុធ ៣ កើតខែមិគសិរ ឆ្នាំជូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សួស-ម៉ី នាមឆាយា ព្រហ្មសរោ កើតឆ្នាំថោះ អាយុ ៥៩ វស្សា ៣៩ ជាចៅអធិការ វត្តសុវណ្ណមោលី ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៧៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ុល-ឡាំ នាមឆាយា ធម្មជោតោ កើតឆ្នាំជូវ អាយុ ៤៩ វស្សា ២៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)